# ហានិភ័យនៃបំណុល

## ការសិក្សាស្រាវជ្រាវបែបបរិមាណនៃ
## អ្នកជាប់ជំពាក់កម្ចីខ្នាតតូចនៅខេត្តកំពង់ស្ពឺ



# ហានិភ័យនៃបំណុល

## ការសិក្សាស្រាវជ្រាវបែបបរិមាណនៃ<br>អ្នកជាប់ជំពាក់កម្ចីខ្នាតតូចនៅខេត្តកំពង់ស្ពឺ

របាយការណ៍រួមចេញផ្សាយ ខែសីហា ឆ្នាំ២០២៣

របាយការណ៍ចេញផ្សាយកន្លងមក៖




[សិទ្ធិទទួលបានការអនុគ្រោះ៖ សំឡេងសហគមន៍ដែលជាប់ជំពាក់បំណុល]

ចេញផ្សាយខែមិថុនា ឆ្នាំ២០២១



[ធ្វើការងាររហូតជំពាក់បំណុលវ័ណ្ឌក៖ ភាពជំពាក់បំណុលច្រើនលើសលុបក្នុងវិស័យកាត់ដេរនៅប្រទេសកម្ពុជា]

ចេញផ្សាយខែមិថុនា ឆ្នាំ២០២០




[ការនាំឱ្យមានចំណាកស្រុក៖ បទពិសោធន៍នៃភូមិមួយអំពីបំណុលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងការចំណាកស្រុកឆ្លងដែន]

ចេញផ្សាយខែឧសភា ឆ្នាំ២០២០




[ការធ្វើឱ្យខូចខាតទ្រព្យដាក់បញ្ចាំ៖ ការបាត់បង់ដីធ្លី និងការរំលោភបំពានក្នុងវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា]

ចេញផ្សាយខែសីហា ឆ្នាំ២០១៩

សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ

**LICADHO**

CAMBODIAN LEAGUE FOR THE PROMOTION
AND DEFENSE OF HUMAN RIGHTS

លីកាដូ គឺជាអង្គការសិទ្ធិមនុស្សជាតិមួយនៅកម្ពុជា ។ ចាប់តាំងពីត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៩២ អង្គការលីកាដូ តែងតែស្ថិតនៅជួរមុខគេ ដើម្បីការពារសិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច និងសិទ្ធិសង្គមរបស់ប្រជាពលរដ្ឋនៅក្នុងប្រទេសកម្ពុជា និងដើម្បីលើកកម្ពស់ ការគោរពសិទ្ធិទាំងនេះពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា និងស្ថាប័នរដ្ឋនានា ។ ដោយបានកសាងនូវសមិទ្ធផលល្អជាច្រើនឆ្នាំកន្លងមក អង្គការលីកាដូ នៅតែបន្តតួនាទីជា អ្នកតស៊ូមតិសម្រាប់ប្រជាពលរដ្ឋ និងជាអ្នកឃ្លាំមើលស្ថានភាពសង្គមតាមរយៈកម្មវិធីឃ្លាំមើល និងការពារសិទ្ធិមនុស្ស ពីទីស្នាក់ការកណ្តាលរបស់ខ្លួននៅរាជធានីភ្នំពេញ និងការិយាល័យនៅតាមសាខា ទាំង ១២ ខេត្តផ្សេងទៀត ។

**អង្គការ សមធម៌កម្ពុជា**

**equitable cambodia**

អង្គការសមធម៌កម្ពុជា គឺជាអង្គការជាតិឈានមុខមួយក្នុងការស្វែងរកការគាំទ្រឱ្យមានការការពារ សិទ្ធិលំនៅដ្ឋាន ដីធ្លី និងធនធានធម្មជាតិនៅកម្ពុជា ។ អង្គការនេះត្រូវបានបង្កើតឡើងនៅឆ្នាំ ២០១២ ដើម្បីលើកកម្ពស់ និងការពារសិទ្ធិរបស់ប្រជាពលរដ្ឋកម្ពុជាទាំងអស់ ពីវិបត្តិនៃការរំលោភបំពានដីធ្លីដ៏រ៉ាំរ៉ៃ និងសិទ្ធិមនុស្ស ។ តាមរយៈការស្រាវជ្រាវគោលនយោបាយ ការស្វែងរកការគាំទ្រនៅថ្នាក់ជាតិ និងអន្តរជាតិ ការបង្កើតក្រុមការងារចម្រុះ និងការរៀបចំចងក្រងសហគមន៍ អង្គការសមធម៌កម្ពុជាខិតខំប្រែក្លាយការអភិវឌ្ឍន៍ដីធ្លី និងសេដ្ឋកិច្ចរបស់ប្រទេស ឱ្យទៅជាគំរូមួយដែលគោរព ការពារ និងបំពេញសិទ្ធិប្រជាជនកម្ពុជាគ្រប់រូប ។ អង្គការសមធម៌កម្ពុជា នឹងសម្រេចគោលដៅរបស់ខ្លួន តាមរយៈកម្មវិធីថាមវន្តបី ដែលកម្មវិធីនីមួយៗខិតខំប្រឹងប្រែង ដើរឆ្ពោះទៅរកចក្ខុវិស័យរបស់ប្រទេសកម្ពុជាមួយដែលប្រជាពលរដ្ឋទាំងអស់ អាចអាស្រ័យបាន ហើយធនធានធម្មជាតិរបស់ប្រទេសត្រូវបានគ្រប់គ្រងប្រកបដោយ សិទ្ធិមនុស្សជាមូលដ្ឋាន ចីរភាពដើម្បីផលប្រយោជន៍រួម ។





# មាតិកា


## សេចក្ដីផ្ដើម — ទំព័រ១

## ខ្លឹមសារសង្ខេប — ទំព័រ៤

## វិធីសាស្ត្រ — ទំព័រ៦

## ការអង្កេតប្រជាសាស្ត្រ — ទំព័រ៨

## បំណុលតាមខ្នងផ្ទះ — ទំព័រ១០

- ទិន្នន័យកម្ចី — ទំព័រ១០
- ហេតុផលក្នុងការខ្ចី — ទំព័រ១១
- ទំហំកម្ចីឥណទានជាមធ្យម — ទំព័រ១៤
- ប្រាក់ចំណូល និងការចំណាយលើការបង់សងបំណុល — ទំព័រ១៥
- ទ្រព្យធានា និងការទទួលបានកម្ចី — ទំព័រ១៧
- ការអាន និងការឈ្វេងយល់អំពីកិច្ចសន្យា — ទំព័រ១៨

## ផលប៉ះពាល់ និងការរំលោភសិទ្ធិមនុស្ស — ទំព័រ២០

- ការលក់ដី និងទ្រព្យសម្បត្តិ ដោយសារបំណុល — ទំព័រ២០
- ផលប៉ះពាល់លើកុមារ (ពលកម្មកុមារ និងការបោះបង់ការសិក្សា) — ទំព័រ២៣
- អសុវត្ថិភាពស្បៀង — ទំព័រ២៦
- ភាពញឹកញាប់នៃផលប៉ះពាល់ — ទំព័រ២៧

## សេចក្ដីសន្និដ្ឋាន — ទំព័រ២៨

## អនុសាសន៍ — ទំព័រ២៩

# សេចក្តីផ្តើម

ការសិក្សាស្រាវជ្រាវដែលចេញផ្សាយក្នុងខែសីហា ឆ្នាំ២០២៣នេះ ត្រូវបានរៀបចំ និងគាំទ្រដោយអង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ (អង្គការលីកាដូ) និងអង្គការសមធម៌កម្ពុជា (អង្គការសមធម៌) ដែលស្ថាប័នទាំង២នេះគឺជាអង្គការមិនមែនរដ្ឋាភិបាល ។ ការសិក្សានេះ ត្រូវបានធ្វើឡើងនៅដើមឆ្នាំ២០២២ អំពីបញ្ហាជាច្រើនឆ្នាំនៃការបន្តកើតមាន និងការកើនឡើងផលប៉ះពាល់នៃវិបត្តិមីក្រូហិរញ្ញវត្ថុ នៅកម្ពុជា ។

នេះគឺជារបាយការណ៍ទី៥ហើយ ដែលត្រូវបានធ្វើឡើងដោយអង្គការលីកាដូ អង្គការសមធម៌ ក៏ដូចជាសហជីព សហគមន៍ អង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការសិទ្ធិមនុស្សនៅក្នុងស្រុកផ្សេងទៀត[1] ដោយរៀបរាប់លម្អិតអំពីការរំលោភសិទ្ធិមនុស្ស ដែលបង្កឡើងដោយវិស័យរកប្រាក់ចំណូលបានខ្ពស់គឺ វិស័យមីក្រូហិរញ្ញវត្ថុ ។ របាយការណ៍ទី១ ត្រូវបានសរសេរនៅក្នុងឆ្នាំ២០១៩ នៅពេលដែលប្រជាពលរដ្ឋ បានជាប់ជំពាក់បំណុលឥណទានខ្នាតតូចចំនួន ៨ពាន់លានដុល្លារសហរដ្ឋអាមេរិក (ដុល្លារ) ហើយក៏ជាពេលដែលទំហំកម្ចីឥណទានធំហួសឆ្ងាយពីប្រាក់ចំណូលរបស់ពួកគេ ។

គិតត្រឹមខែមីនា ឆ្នាំ២០២៣នេះ ផលប័ត្រឥណទានខ្នាតតូច បានកើនដល់ជាង ១៦ ពាន់លានដុល្លារ ក្នុងចំណោមកម្ចីឥណទានសរុបចំនួន ២,៨៩ លានកម្ចី ជាតួលេខដ៏ធំសម្បើមមួយដែលតំណាងឱ្យជិតពាក់កណ្តាលនៃផលិតផលក្នុងស្រុកសរុបរបស់ប្រទេសកម្ពុជា ជាបំណុលឥណទានខ្នាតតូច ។ កម្ចីឥណទានទាំងនេះ បានមកពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចុះបញ្ជីផង និងក្រុមធនាគារដែលពីមុនធ្លាប់ជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប៉ុន្តែនៅរក្សាផលប័ត្រឥណទានខ្នាតតូចដដែលផង ។ ការកើនឡើងហួសប្រមាណនៃការផ្តល់កម្ចី បាននាំឱ្យប្រជាពលរដ្ឋជាច្រើន មានអស្ថិរភាពនៃកម្រិតបំណុល ដែលគួរឱ្យព្រួយបារម្ភ ។

របាយការណ៍មុនៗរបស់អង្គការមិនមែនរដ្ឋាភិបាល បានប្រើប្រាស់វិធីសាស្ត្របែបគុណភាព (qualitative) ដើម្បីបង្ហាញលម្អិតពីផលប៉ះពាល់ធ្ងន់ធ្ងរ ដែលបង្កឡើងដោយបំណុលមីក្រូហិរញ្ញវត្ថុ ដែលកំពុងកើនឡើងយ៉ាងគំហុកនេះ ។ ផលប៉ះពាល់ទាំងនេះ រួមមាន ការលក់ដីដោយបង្ខំ ពលកម្មកុមារ ចំណាកស្រុកដោយអសុវត្ថិភាព ភាពអត់ឃ្លាន ការបំភិតបំភ័យ និងគំរាមកំហែង ក៏ដូចជាការបង្ខិតបង្ខំដោយប្រើប្រាស់អាជ្ញាធរ និងផលប៉ះពាល់ផ្សេងទៀត ។ របាយការណ៍ទាំងនេះ ត្រូវបានធ្វើឡើងយ៉ាងជិតស្និទ្ធជាមួយប្រជាសហគមន៍ និងអ្នកខ្ចីប្រាក់រាប់រយនាក់ ដើម្បីប្រមូលយកបទពិសោធន៍របស់អ្នកខ្ចីប្រាក់ និងបន្លឺសំឡេងប្រជាពលរដ្ឋ ដែលរងផលប៉ះពាល់ច្រើនជាង គេ នៅក្នុងវិស័យនេះ ។

ការឆ្លើយតបដ៏ច្រើនលើសលប់ពីសំណាក់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ធនាគារ ប្រតិបត្តិករ និងវិនិយោគិនអន្តរជាតិ គឺជាការបដិសេធទៅលើរបាយការណ៍ទាំងនោះ ដោយផ្អែកលើហេតុផល

**គិតត្រឹមខែមីនា ឆ្នាំ២០២៣ វិស័យឥណទានខ្នាតតូច បានកើនដល់ជាង ១៦ ពាន់លានដុល្លារ ក្នុងចំណោមកម្ចីឥណទានសរុបចំនួន ២,៨៩ លានកម្ចី**

**ការកើនឡើងយ៉ាងគំហុកនេះ បានធ្វើឱ្យប្រជាពលរដ្ឋជាច្រើនធ្លាក់ក្នុងអស្ថិរភាពនៃបំណុល**

**ប្រជាពលរដ្ឋជាង ១៦៧.០០០ នាក់ បានលក់ដី ដោយសារភាពជំពាក់បំណុលច្រើនលើសលប់ នៅពាក់កណ្តាលទសវត្សរ៍ចុងក្រោយ**

[1] របាយការណ៍របស់អង្គការលីកាដូ និងអង្គការសមាគមធាងត្នោត ស្តីពី "ការធ្វើឱ្យខូចខាតទ្រព្យដាក់បញ្ចាំ៖ ការបាត់បង់ដីធ្លី និងការរំលោភបំពានក្នុងវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា" ចេញផ្សាយ កាលពីខែសីហា ឆ្នាំ២០១៩ ដកស្រង់ពី៖ https://www.mficambodia.com/reports/Report-CollateralDamage-2019-km.pdf

របាយការណ៍របស់អង្គការលីកាដូ ស្តីពី "ការនាំឱ្យមានចំណាកស្រុក៖ បទពិសោធន៍នៃភូមិមួយអំពីបំណុលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងការចំណាកស្រុកឆ្លងដែន" ចេញផ្សាយ កាលពីខែឧសភា ឆ្នាំ២០២០ ដកស្រង់ពី៖ https://www.mficambodia.com/reports/Report-DrivenOut-2020-km.pdf

របាយការណ៍របស់អង្គការលីកាដូ អង្គការសង់ត្រាល់ និងសហព័ន្ធសហជីពកម្ពុជា ស្តីពី "ធ្វើការងាររហូតជំពាក់បំណុលវណ្ឌកៈ ភាពជំពាក់បំណុលច្រើនលើសលុបក្នុងវិស័យកាត់ដេរនៅប្រទេសកម្ពុជា" ចេញផ្សាយ កាលពីខែមិថុនា ឆ្នាំ២០២០ ដកស្រង់ពី៖ https://www.mficambodia.com/reports/Report-WorkedToDebt-2020-km.pdf

របាយការណ៍របស់អង្គការលីកាដូ និងអង្គការសមធម៌កម្ពុជា ស្តីពី "សិទ្ធិទទួលបានការអនុគ្រោះ៖ សំឡេងសហគមន៍ដែលជាប់ជំពាក់បំណុល" ចេញផ្សាយ កាលពីខែមិថុនា ឆ្នាំ២០២១ ដកស្រង់ពី៖ https://www.mficambodia.com/reports/Report-RightToRelief-2021-km.pdf

នៃវិធីសាស្ត្រសិក្សាស្រាវជ្រាវ ជាពិសេសគឺថា ការសិក្សាបែបគុណភាព មិនមែនជាការស្ទង់មតិបែបបរិមាណ ហេតុដូច្នេះហើយពួកគេលើកឡើងថា ស្ថិតិទាំងនេះមិនអាចយកធ្វើជាតំណាងបានទេ ។ ការរិះគន់ទាំងនេះ ត្រូវបានប្រើប្រាស់ជាញឹកញាប់ ដើម្បីបង្វែរការចាប់អារម្មណ៍ និងបដិសេធទៅលើបញ្ហានេះ និងដើម្បីធ្វើឱ្យមើលឃើញថា ត្រឹមត្រូវ អំពីការបន្ត "អាជីវកម្មដូចធម្មតា" នៅក្នុងអាជីវកម្មរកប្រាក់ចំណេញបានខ្ពស់ ពីការផ្តល់កម្ចីបែបកេងប្រវ័ញ្ច ។

**ការស្រាវជ្រាវនេះ គឺជាការស្ទង់មតិតំណាងឱ្យស្ថានភាពប្រជាពលរដ្ឋតាមខ្នងផ្ទះ ដែលជាប់ជំពាក់បំណុលនៅក្នុងខេត្តកំពង់ស្ពឺ**

ការរិះគន់ទាំងនេះ នៅតែបន្តកើតមានជាច្រើនឆ្នាំ ទោះបីជាវិនិយោគិនអន្តរជាតិបានអះអាងថា សូម្បីតែការបំពាន ឬការរំលោភគោលការណ៍មួយក៏ធ្ងន់ធ្ងរដែរ និងទោះបីជាទ្រឹស្តីមូលដ្ឋានដែលថាសិទ្ធិមនុស្សគឺអនុវត្តសម្រាប់មនុស្សគ្រប់គ្នា មិនមែនអនុវត្តសម្រាប់តែអ្នកដែលនៅក្នុងទំហំគំរូធំនោះទេ ហើយនិងទោះបីជាតម្លៃភស្តុតាងដែលបង្ហាញឱ្យឃើញខ្លួនឯងនៃការស្រាវជ្រាវតាមសហគមន៍ ក្នុងការបន្លឺសំឡេងរបស់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ក៏ដោយ ។

ក្នុងពេលជាមួយគ្នានេះដែរ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ធនាគារ និងវិនិយោគិនអន្តរជាតិរបស់ពួកគេជាច្រើនទៀត បានខកខានក្នុងការសិក្សាស្រាវជ្រាវបែបបរិមាណជាសាធារណៈ និងដោយឯករាជ្យ ទៅលើការវិភាគរបស់ពួកគេចំពោះបញ្ហាទាំងនេះ ។

នៅដើមឆ្នាំ២០២២ អង្គការលីកាដូ និងអង្គការសមធម៌ បានរៀបចំ និងគាំទ្រ ក្រុមទីប្រឹក្សាមកពីក្រៅស្ថាប័ន ដើម្បីធ្វើការសិក្សាមួយ ។ ដោយសារថវិកាមានកំណត់ ការសិក្សានេះបានផ្តោតសំខាន់តែខេត្តកំពង់ស្ពឺមួយប៉ុណ្ណោះ ដែលជាខេត្តមានទំហំធំ ប្រជាពលរដ្ឋច្រើន និងនៅជិតរាជធានីភ្នំពេញ ហើយក៏ជាខេត្តដែលស្ថិតនៅជិតកម្រិតមធ្យមនៃប្រាក់ចំណូល និងភាពក្រីក្រ នៅក្នុងប្រទេស ផងដែរ ។[2] ការស្រាវជ្រាវនេះ គឺជាការស្ទង់មតិតំណាងឱ្យស្ថានភាពប្រជាពលរដ្ឋតាមខ្នងផ្ទះ ដែលជាប់ជំពាក់បំណុល នៅក្នុងខេត្តកំពង់ស្ពឺនេះ ។

**បច្ចុប្បន្ននេះ ប័ណ្ណកម្មសិទ្ធិដីធ្លី នៅតែត្រូវបានប្រើប្រាស់ជាទ្រព្យធានាយ៉ាងទូលំទូលាយ សម្រាប់កម្ចីឥណទានខ្នាតតូច នៅកម្ពុជា**

នៅចន្លោះពេលនៃការធ្វើរបាយការណ៍នេះ និងការចេញផ្សាយ ការស្ទង់មតិបែបបរិមាណ (quantitative) ផ្សេងមួយទៀត ត្រូវបានធ្វើឡើង និងចេញផ្សាយ ក្រោមជំនួយថវិការបស់ក្រសួងអភិវឌ្ឍន៍ និងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច អាឡឺម៉ង់ ហៅកាត់ថា BMZ ។ រដ្ឋាភិបាលអាឡឺម៉ង់បានផ្តល់ថវិកាវិនិយោគរាប់សែនលានដុល្លារដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងធនាគារនៅកម្ពុជានៅរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ តាមរយៈ BMZ និងធនាគារអភិវឌ្ឍន៍អាឡឺម៉ង់ KfW ។ នៅក្នុងឆ្នាំ២០២២ ពួកគេបានជួល វិទ្យាស្ថានសម្រាប់ការអភិវឌ្ឍ និងសន្តិភាព (INEF) ដែលជាស្ថាប័នស្រាវជ្រាវមានមូលដ្ឋាននៅក្នុងប្រទេសអាឡឺម៉ង់ ឱ្យធ្វើការសិក្សាបែបបរិមាណទៅលើវិស័យនេះ ។

តាមការចេញផ្សាយនៅក្នុងខែសីហា ឆ្នាំ២០២២ របាយការណ៍របស់ INEF បានរកឃើញថា មានការព្រួយបារម្ភពីការលក់ដីដោយសារការជំពាក់បំណុលជាច្រើនករណី ពោលក្នុងកម្រិតមួយ "ខ្ពស់ខ្លាំង" និង "មិនអាចទទួលយកបាន" និងទំហំកម្ចីឥណទានមធ្យមក្នុងកម្រិតខ្ពស់ខ្លាំង ប្រៀបធៀបទៅនឹងទីផ្សារមីក្រូហិរញ្ញវត្ថុផ្សេងទៀត ហើយនិងការរំលោភសិទ្ធិមនុស្ស

[2] ផ្អែកលើការគណនានៅក្នុង "របាយការណ៍សង្ខេបសន្ទស្សន៍សកលពហុវិមាត្រនៃភាពក្រីក្រឆ្នាំ២០១៨៖ ប្រទេសកម្ពុជា (អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក)" ដោយការផ្តួចផ្តើមការអភិវឌ្ឍន៍ធនធានមនុស្ស និងចាកចេញពីភាពក្រីក្ររបស់ Oxford ទំព័រទី៩ ដកស្រង់ពី៖ https://ophi.org.uk/wp-content/uploads/CB_KHM-2.pdf

"ជាច្រើនករណី" ក៏ដូចជា "ការអនុវត្តជាញឹកញាប់" ដូចៗគ្នានៃការកាត់បន្ថយអាហារបរិភោគដើម្បីសន្សំប្រាក់ទុកសងបំណុល ។ អ្នកសរសេររបាយការណ៍នេះ បានកត់សម្គាល់ថា "បញ្ហារបស់កូនបំណុលដែលត្រូវបានសម្ភាស និងរៀបរាប់នៅក្នុងការសិក្សាតាមភូមិរបស់អង្គការពីរ [អង្គការលីកាដូ និងអង្គការសមធម៌] [...]គឺមិនអាចបដិសេធបានទេ និងត្រូវបញ្ជាក់ដោយបទសម្ភាសន៍បន្ថែមទៀត ។ ជារួម ករណីទាំងនេះគឺទំនងជាមានច្រើន និងអាចកើតមាននៅទូទាំង[៣]ប្រទេសផងដែរ" ។

របាយការណ៍នេះ បានប៉ាន់ប្រមាណថា ប្រជាពលរដ្ឋខ្មែរជាង ១៦៧.០០០ នាក់ បានលក់ដី ដោយសារភាពជាប់ជំពាក់បំណុលនៅក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយ ដែលជាការរកឃើញពីគ្រោះថ្នាក់នៃការរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ ដែលកំពុងបន្តកើតមាន និងជារឿយៗត្រូវបានមើលរំលង ។ ការរកឃើញនៅក្នុងរបាយការណ៍របស់INEF ភាគច្រើនគឺស៊ីចង្វាក់គ្នានឹងការសិក្សានេះ ដែលផ្តល់ជាភស្តុតាងបែបបរិមាណបន្ថែមទៀត ទៅលើផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ក៏ដូចជាការរំលោភសិទ្ធិមនុស្ស នៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ និងកម្ចីឥណទានខ្នាតតូច នៅកម្ពុជា ។

បច្ចុប្បន្ននេះ ប័ណ្ណកម្មសិទ្ធិដីធ្លី គឺនៅតែត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយ ធ្វើជាទ្រព្យធានាសម្រាប់កម្ចីឥណទានខ្នាតតូចនៅកម្ពុជា ថវិការាប់រយលានដុល្លារពីស្ថាប័នអភិវឌ្ឍន៍របស់រដ្ឋ និងធនាគារអភិវឌ្ឍន៍ពហុភាគី នៅតែបន្តផ្តល់ឱ្យទៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងធនាគារនៅកម្ពុជា ដោយផ្ទាល់ និងតាមរយៈមូលនិធិវិនិយោគដូចជា មូលនិធិពង្រឹងសមត្ថភាពមីក្រូហិរញ្ញវត្ថុ (MEF) ដោយពុំមានដំណោះស្រាយឬការអនុគ្រោះដល់អ្នកខ្ចីប្រាក់ពីសំណាក់វិនិយោគិន ឬគ្រឹះស្ថានហិរញ្ញវត្ថុណាមួយនោះទេ ហើយក៏មិនមានការអនុវត្តកិច្ចការពារអ្នកប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពពីសំណាក់រាជរដ្ឋាភិបាលផងដែរ ។ ជំងឺកូវីដ-១៩ និងការរៀបចំឥណទានឡើងវិញបណ្តោះអាសន្ន បាននាំឱ្យអ្នកខ្ចីប្រាក់ជាច្រើននាក់ជាប់ផុងក្នុងបំណុលកាន់តែជ្រៅ និងបង្កើនបន្ទុកបំណុលកាន់តែធំ[៤] ។

វិនិយោគិនណាមួយដែលនៅតែមិនជឿលើការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរយ៉ាងទូលំទូលាយនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជាក្នុងឆ្នាំ២០២៣នេះ គឺកំពុងតែមានចេតនាមើលរំលងភស្តុតាងទាំងនេះ ។ ទាំងវិនិយោគិនបច្ចុប្បន្ន និងវិនិយោគិនដែលបានចាកចេញថ្មីៗនេះ ត្រូវតែទទួលខុសត្រូវចំពោះផលប៉ះពាល់នៃសកម្មភាព និងការវិនិយោគរបស់ពួកគេ ហើយត្រូវចាត់វិធានការភ្លាមៗ ដើម្បីដោះស្រាយផលប៉ះពាល់ដែលពួកគេបានរួមចំណែក ក៏ដូចជាត្រូវធ្វើឱ្យការវិនិយោគរបស់ពួកគេស្របតាមបទដ្ឋានជាតិ និងអន្តរជាតិ ។

**ទាំងវិនិយោគិនបច្ចុប្បន្ន និងវិនិយោគិនដែលបានចាកចេញត្រូវតែទទួលខុសត្រូវ ចំពោះផលប៉ះពាល់នៃសកម្មភាព និងការវិនិយោគរបស់ពួកគេ**

[៣] របាយការណ៍របស់ វិទ្យាស្ថានសម្រាប់ការអភិវឌ្ឍន៍ និងសន្តិភាព (INEF) ស្តីពី "មីក្រូ" ហិរញ្ញវត្ថុនៅកម្ពុជា៖ ការអភិវឌ្ឍន៍ បញ្ហាប្រឈម និងអនុសាសន៍" ដកស្រង់ពី៖ https://geswiss-ude.de/wp-content/uploads/2023/01/AVE-30-b-micro-finance-in-cambodia.pdf

[៤] សូមមើល "ផលប៉ះពាល់នៃជំងឺកូវីដ-១៩ ទៅលើមីក្រូហិរញ្ញវត្ថុ និងគ្រួសារងាយរងគ្រោះ" ដោយ ផេះ ផាស៊ី មជ្ឈមណ្ឌលខេមរសិក្សា ដកស្រង់ពី៖ https://khmerstudies.org/covid-19-impacts-on-microfinance-and-vulnerable-households/

# ខ្លឹមសារសង្ខេប

**២៧,៣%**

នៃប្រជាពលរដ្ឋតាមខ្នងផ្ទះសរុប កំពុងចំណាយប្រាក់ចំណូលជាង ៧០% បង់សងបំណុល ជារៀងរាល់ខែ

**៩៣,១%**

នៃខ្នងផ្ទះសរុប ត្រូវបានតម្រូវឱ្យដាក់ប័ណ្ណកម្មសិទ្ធិដីធ្លីយ៉ាងតិចមួយ ជាទ្រព្យធានាសម្រាប់កម្ចីឥណទានខ្នាតតូចមួយ

**៦,១%**

នៃខ្នងផ្ទះសរុប បានលក់ដីយ៉ាងតិចម្តង ដើម្បីបង់សងកម្ចីមីក្រូហិរញ្ញវត្ថុ ឬធនាគារ

ការរកឃើញសំខាន់ៗខាងក្រោមនេះ គឺជាការស្ទង់មតិតំណាងឱ្យប្រជាពលរដ្ឋចំនួន ៧១៧ខ្នងផ្ទះ ដែលបានយកកម្ចីឥណទានពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងធនាគារ នៅគ្រប់ស្រុកក្នុងខេត្តកំពង់ស្ពឺ ។ សំណួរស្ទង់មតិ គឺផ្តោតសំខាន់ជុំវិញផលប៉ះពាល់នៃកម្ចីចំនួន ១.៧៤៥ ដែលប្រជាពលរដ្ឋទាំងនេះបានរាយការណ៍ និងបានយកក្នុងរយៈពេល ១០ឆ្នាំចុងក្រោយនេះ រួមមានកម្ចីចំនួន ៨២៩ នៅបន្តបង់សងនៅឡើយ គិតត្រឹមពេលស្ទង់មតិនេះ ។ ខណៈដែលមានការប្រមូលទិន្នន័យចំនួន ១៣២ នៃកម្ចី "មិនផ្លូវការ" របស់អ្នកផ្តល់ប្រាក់កម្ចីដែលមិនបានចុះបញ្ជីត្រឹមត្រូវ សំណួរស្ទង់មតិបានផ្តោតលើការខូចខាត និងផលប៉ះពាល់ ដែលកើតចេញពីកម្ចីផ្លូវការចំនួន ១.៦១៣ ដោយសារនេះគឺជាកន្លែងដែលទឹកប្រាក់រាប់ពាន់លានដុល្លាររបស់វិនិយោគអន្តរជាតិ ត្រូវបានប្រើប្រាស់ ។

**អ្នកខ្ចីប្រាក់ជាច្រើននាក់ ជាប់ជំពាក់បំណុលច្រើនលើសលប់ ។** ច្រើនជាង ២/៣ នៃអ្នកខ្ចីប្រាក់ទាំងអស់ "យល់ស្រប" ឬ "យល់ស្របទាំងស្រុង" ថា ពួកគេនៅតាមខ្នងផ្ទះ ជាប់ជំពាក់បំណុលច្រើនខ្លាំងពេក ។ ច្រើនជាង ១/៤ (២៧,៣%) នៃអ្នកផ្តល់បទសម្ភាសន៍ កំពុងយកប្រាក់ចំណូលរបស់ពួកគេជាង ៧០% បង់សងបំណុល ជារៀងរាល់ខែ ដែលនេះជាការរំលោភបំពានទៅលើស្តង់ដារឧស្សាហកម្មដែលហៅថា ការផ្តល់កម្ចីប្រកបដោយក្រមសីលធម៌ ។[៥] ចំណុចដែលគួរឱ្យព្រួយបារម្ភនោះគឺ ប្រមាណ ១០% នៃអ្នកផ្តល់បទសម្ភាសន៍ កំពុងបង់សងបំណុលជារៀងរាល់ខែក្នុងទំហំច្រើនជាងប្រាក់ចំណូលដែលពួកគេរកបាន ។ កម្រិតនៃភាពជំពាក់បំណុលច្រើនលើសលប់នេះ បានធ្វើឱ្យប្រជាពលរដ្ឋនៅតាមខ្នងផ្ទះ ធ្លាក់ចូលក្នុងស្ថានភាពអាក្រក់កាន់តែខ្លាំងដូចជា កាត់បន្ថយអាហារបរិភោគ ឱ្យកូនឈប់រៀន ឬលក់ដីដើម្បីសងបំណុលជាដើម ។

**ស្ទើរតែគ្រប់ពេល ប័ណ្ណកម្មសិទ្ធិដីធ្លីត្រូវបានតម្រូវ សម្រាប់ការយកកម្ចីមីក្រូហិរញ្ញវត្ថុ ។** អ្នកផ្តល់បទសម្ភាសន៍ជាង ៩២% បានដាក់ប័ណ្ណកម្មសិទ្ធិដីធ្លីយ៉ាងតិចមួយ ជាទ្រព្យធានាដើម្បីទទួលបានកម្ចីឥណទានខ្នាតតូច មានន័យថា អ្នកខ្ចីប្រាក់ប្រឈមនឹងការបាត់បង់ដីធ្លីប្រសិនបើពួកគេគ្មានលទ្ធភាពបង់សងកម្ចីនោះវិញ ។ ករណីនេះ គឺស៊ីចង្វាក់គ្នានឹងរបាយការណ៍ប្រចាំឆ្នាំរបស់អ្នកផ្តល់ប្រាក់កម្ចីជាច្រើននៅកម្ពុជា ដែលបង្ហាញពីផលប័ត្រឥណទាន ដែលថាជាង ៩៥% នៃកម្ចី គឺមានការដាក់ទ្រព្យធានា ។[៦]

**ការលក់ដីដោយសារបំណុល កើតឡើងញឹកញាប់ណាស់ ។** ៦,១% នៃចំនួនខ្នងផ្ទះសរុប បានលក់ដីយ៉ាងតិចម្តង ដើម្បីបង់សងកម្ចីមីក្រូហិរញ្ញវត្ថុ ឬធនាគារ ជាអត្រាមួយស្រដៀងទៅនឹងការរកឃើញនៅក្នុងរបាយការណ៍ INEF (៦,២%) កាលពីខែកញ្ញា ឆ្នាំ២០២២ ។[៧] ភាគ

[៥] សូមមើល "របាយការណ៍ប្រចាំឆ្នាំ២០២២របស់ធនាគារអេស៊ីលីដា" ទំព័រ១៣៦-១៣៧ (៩៦,៤២% មានដាក់ទ្រព្យធានា) ដកស្រង់ពី៖ https://www.acledabank.com.kh/kh/assets/pdf_zip/ACLEDA-AR2022-SERC-Eng.pdf និងសេចក្តីថ្លែងការណ៍ហិរញ្ញវត្ថុសម្រាប់ឆ្នាំបិទបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងរបាយការណ៍សវនកម្មឯករាជ្យ របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ ទំព័រ ៨២-៨៣ (៩៩,៨% មានដាក់ទ្រព្យធានា) ដកស្រង់ពី៖ https://www.prasac.com.kh/wp-content/uploads/2022/04/PRASAC_AuditedFinancial-Statements-31-Dec-2021_EN.pdf

[៦] របាយការណ៍របស់ វិទ្យាស្ថានសម្រាប់ការអភិវឌ្ឍន៍ និងសន្តិភាព (INEF) ស្តីពី "មីក្រូ" ហិរញ្ញវត្ថុនៅកម្ពុជា៖ ការអភិវឌ្ឍន៍ បញ្ហាប្រឈម និងអនុសាសន៍" ទំព័រទី៧៣ ដកស្រង់ពី៖ https://geswiss-ude.de/wp-content/uploads/2023/01/AVE-30-b-micro-finance-in-cambodia.pdf

[៧] "អ្នកផ្តល់ប្រាក់កម្ចីធំៗ" ទីនេះ សំដៅលើគ្រឹះស្ថាន ដែលកាន់កាប់កម្ចីយ៉ាងតិច១%នៅក្នុងការស្ទង់មតិនេះ ។

**២,៩៣%**

នៃខ្នងផ្ទះសរុប មានកុមារយ៉ាងតិចម្នាក់តាមផ្ទះនីមួយៗដែលបោះបង់ការសិក្សា ដោយសារកម្ចីមីក្រូហិរញ្ញវត្ថុ ឬធនាគារ

**១៨,៣%**

នៃខ្នងផ្ទះសរុប បានកាត់បន្ថយអាហារបរិភោគ ក្រោយពេលយកកម្ចីឥណទានពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬធនាគារ

**៣៤,៨%**

នៃកម្ចីសរុប គឺយកទៅបង់សងបំណុលដែលមានស្រាប់ក្នុងឆ្នាំ២០២២

**១,៤%**

នៃអ្នកផ្តល់បទសម្ភាសន៍ បានគិតថា ដីធ្លីរបស់ពួកគេ នឹងត្រូវរឹបអូស តាមដំណើរការតុលាការ ប្រសិនបើពួកគេ មិនអាចបង់សងកម្ចីមីក្រូហិរញ្ញវត្ថុ ឬធនាគារទេ

ច្រើននៃដីដែលបានលក់គឺជាដីកសិកម្ម ប៉ុន្តែ ៨ករណី ក្នុងចំណោមការលក់ដីចំនួន ៤៨ គឺជាដីលំនៅឋាន ដោយបានបញ្ជាក់ថា កម្ចីមីក្រូហិរញ្ញវត្ថុគឺជាហេតុផលដែលនាំឱ្យប្រជាពលរដ្ឋបាត់បង់ទាំងផ្ទះសម្បែង និងជីវភាពរបស់ពួកគេ ។ ការអនុវត្តបែបនេះគឺកើតឡើងជាទូទៅ ដោយយ៉ាងតិចណាស់មានការលក់ដីមួយ ដើម្បីបង់សងអ្នកផ្តល់ប្រាក់កម្ចីធំៗនៅក្នុងការស្ទង់មតិនេះ ។[៨]

**ពលកម្មកុមារត្រូវបានប្រើប្រាស់ ដើម្បីបង់សងបំណុលមីក្រូហិរញ្ញវត្ថុ ។** ប្រមាណជា ៣% នៃខ្នងផ្ទះសរុប មានកុមារយ៉ាងតិចម្នាក់តាមផ្ទះនីមួយៗដែលបោះបង់ការសិក្សា ដោយសារកម្ចីមីក្រូហិរញ្ញវត្ថុ ពោលគឺមានកុមារសរុបចំនួន៤១នាក់ ។ ជារួម កុមារចំនួន ៥១នាក់ អាយុក្រោម ១៨ឆ្នាំ បានកំពុងធ្វើការដើម្បីរកប្រាក់សងកម្ចីមីក្រូហិរញ្ញវត្ថុ ឬធនាគារ ហើយក្នុងនោះមានកុមារ៤៩នាក់បានបោះបង់ការសិក្សា និង១២នាក់គឺមានអាយុក្រោម១៥ឆ្នាំ ។

**អ្នកខ្ចីប្រាក់បរិភោគអាហារតិចជាងពេលដែលមិនទាន់យកកម្ចីឥណទាន ។** ជិត១/៥ (១៨,៣%) នៃចំនួនខ្នងផ្ទះបាននិយាយថា ពួកគេ បានកាត់បន្ថយការបរិភោគអាហារក្រោយពេលយកកម្ចីឥណទានពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬធនាគារ ដោយមានតែ ៤,៥% ប៉ុណ្ណោះដែលនិយាយថា ពួកគេបរិភោគអាហារច្រើនជាងមុនក្រោយពេលយកកម្ចីឥណទាន ។ ក្នុងចំណោម ៨,៥% នៃចំនួនខ្នងផ្ទះដែលបានលើកឡើងថា មិនមានអាហារបរិភោគគ្រប់គ្រាន់ (៦១ខ្នងផ្ទះ) ក្នុងនោះមានប្រជាពលរដ្ឋជាងពាក់កណ្តាល (៣៧ខ្នងផ្ទះ) ក៏បាននិយាយថា កម្ចីមីក្រូហិរញ្ញវត្ថុ ឬធនាគាររបស់ពួកគេ បានធ្វើឱ្យពួកគេកាត់បន្ថយអាហារបរិភោគ ។

**ប្រជាពលរដ្ឋកំពុងបង្កើនការយកកម្ចីផ្សេងទៀត ដើម្បីបង់សងបំណុលដែលមានស្រាប់ ។** អ្នកផ្តល់បទសម្ភាសន៍បានលើកឡើងថា នៅក្នុងឆ្នាំ២០១២ កម្ចីឥណទានត្រឹមតែ ៣,៤៥% ប៉ុណ្ណោះ ដែលត្រូវបានយកទៅបង់សងកម្ចីឥណទានដទៃទៀត ។ ប៉ុន្តែនៅក្នុងឆ្នាំ២០២២ "ការខ្ចីយកទៅបង់សង" គឺជាហេតុផលកើតឡើងញឹកញាប់ជាងគេក្នុងការយកកម្ចីថ្មី ដោយមាន ៣៤,៨% នៃកម្ចីសរុប មានន័យថាជាង ១/៣ នៃបំណុលក្នុងឆ្នាំ២០២២ គឺដើម្បីបង់សងបំណុលដែលមានស្រាប់ ។ នេះគឺជាសញ្ញាយ៉ាងច្បាស់ពីចំណុចគួរឱ្យព្រួយបារម្ភនៃកម្រិតជំពាក់បំណុលច្រើនលើសលប់ និងជាបរាជ័យនៃការអនុវត្តវិធានការដែលមានស្រាប់ ដើម្បីដោះស្រាយបញ្ហាបំណុលនេះ ។

**ស្ទើរតែគ្មាននរណាម្នាក់ជឿថា ដំណើរការផ្លូវច្បាប់ត្រឹមត្រូវសម្រាប់ការរឹបអូសអាចនឹងកើតមានឡើងនោះទេ ក្នុងករណីដែលកូនបំណុលខកខានបង់សង ។** ទោះបីជាជាង ៩២% នៃចំនួនខ្នងផ្ទះ ដែលបានដាក់ប័ណ្ណកម្មសិទ្ធិដីធ្លីធ្វើជាទ្រព្យធានា មានតែ ៤៤,២% ប៉ុណ្ណោះដែលជឿថា អ្នកផ្តល់កម្ចីឥណទានរបស់ពួកគេ អាចនឹងរឹបអូសដីធ្លីរបស់ពួកគេ ប្រសិនបើខកខានការបង់សង ។ ក្នុងចំណោមអ្នកដែលគិតថាដីរបស់ពួកគេអាចនឹងត្រូវបានរឹបអូស គឺមានតែ ៣,២% ប៉ុណ្ណោះដែលបានគិតថា ដំណើរការនៃការរឹបអូសនឹងពាក់ព័ន្ធជាមួយតុលាការ (១,៤%នៃអ្នកផ្តល់បទសម្ភាសន៍) ដែលជាមធ្យោបាយផ្លូវច្បាប់តែមួយគត់សម្រាប់អ្នកផ្តល់កម្ចីឥណទាន ដើម្បីប្រមូលទ្រព្យធានាតាមច្បាប់កម្ពុជា ។ អ្នកខ្ចីប្រាក់ភាគច្រើនបានជឿថា ដីរបស់ពួកគេអាចនឹងត្រូវរឹបអូសដោយអាជ្ញាធរ (៤០,៧%) ឬមន្ត្រីឥណទាន (៣២,៥%) ឬមិនដឹងថាអ្នកណាដែលទទួលខុសត្រូវក្នុងការរឹបអូស (៣៤,១%) ។ នេះបង្ហាញថា ព័ត៌មានចាំបាច់អំពីសិទ្ធិកូនបំណុល និងការទទួលខុសត្រូវ នៅពេលដែលមានការខកខានបង់សង គឺមិនត្រូវបានពន្យល់ ឬឈ្វេងយល់ឱ្យបានច្បាស់លាស់សម្រាប់អ្នកខ្ចីប្រាក់ភាគច្រើននោះទេ ។

[៨] "អ្នកផ្តល់ប្រាក់កម្ចីធំៗ" ទីនេះ សំដៅលើគ្រឹះស្ថាន ដែលកាន់កាប់កម្ចីយ៉ាងតិច១%នៅក្នុងការស្ទង់មតិនេះ ។

# វិធីសាស្ត្រ

ការសិក្សានេះ បានប្រើប្រាស់ក្រុមប្រមូលទិន្នន័យពីក្រៅស្ថាប័ន ដើម្បីសាកសួរសំណួរស្ទង់មតិយ៉ាងទូលំទូលាយអំពីផលប៉ះពាល់ទៅលើសិទ្ធិមនុស្ស និងការអភិវឌ្ឍ ចំពោះបំណុលមីក្រូហិរញ្ញវត្ថុ ឬធនាគារ ខណៈដែលបញ្ជីសំណួរត្រូវបានបង្កើតឡើងដោយទីប្រឹក្សាក្រៅស្ថាប័ន និងត្រួតពិនិត្យដោយអង្គការលីកាដូ និងសមធម៌កម្ពុជា ។ ក្រុមនេះបានប្រើប្រាស់ វិធីសាស្ត្របរិមាណ ដើម្បីធានាថា ការស្ទង់មតិ គឺជាតំណាងនៅទូទាំងខេត្តកំពង់ស្ពឺ ។

អ្នកផ្តល់បទសម្ភាសន៍ ត្រូវបានកំណត់ ដោយប្រើប្រាស់វិធីសាស្ត្រជ្រើសរើសគំរូដោយចៃដន្យ ។ ខេត្តកំពង់ស្ពឺ ត្រូវបានជ្រើសរើស ដោយសារតែវាជាខេត្តធំជាងគេទី៣ នៅក្នុងលក្ខខណ្ឌនៃទំហំកម្ចីឥណទានមិនទាន់សងរួច (តាមពីក្រោយរាជធានីភ្នំពេញ និងខេត្តសៀមរាប) ហើយវាមានតួលេខប្រហាក់ប្រហែលគ្នានៃកម្ចីមីក្រូហិរញ្ញវត្ថុ ឬធនាគារ ដែលដូចគ្នានឹងចំនួនខ្នងផ្ទះ (គិតត្រឹមពាក់កណ្តាលឆ្នាំ២០២១) ។ ការធ្វើបញ្ជីខ្នងផ្ទះក្នុងកម្រិតតាមភូមិ ត្រូវបានប្រើប្រាស់ ដើម្បីកំណត់អ្នកផ្តល់បទសម្ភាសន៍ និងជ្រើសរើសខ្នងផ្ទះដោយចៃដន្យ ។

អ្នកគ្រប់គ្រងចំនួន២នាក់ ត្រូវបានបញ្ជូនចុះទៅតាមភូមិ ជាង ១០ថ្ងៃ ក្នុងខែមិថុនា និងខែកក្កដា ឆ្នាំ២០២២ ដើម្បីបំពេញបញ្ជីខ្នងផ្ទះ សម្រាប់ជ្រើសរើសចំនួនខ្នងផ្ទះគោលដៅចំនួន ៨០០ ។ ដោយមានបញ្ជីខ្នងផ្ទះនៅក្នុងដៃ អ្នកជំនាញខាងគំរូ បានជ្រើសរើសគំរូទាំងនោះ ជាមួយនឹងឈ្មោះខ្នងផ្ទះនីមួយៗមកពីភូមិនីមួយៗ ។

ក្រោយមក ក្រុមទីប្រឹក្សាបានដាក់ពង្រាយអ្នកស្ទង់មតិដោយប្រើប្រាស់កម្មវិធី KoboToolbox ដែលអាចប្រើប្រាស់បានជាមួយប្រព័ន្ធប្រតិបត្តិការAndroid របស់ទូរស័ព្ទឬថេបប្លេត ក្នុងការប្រមូលទិន្នន័យ ។ ទិន្នន័យត្រូវបានគ្រប់គ្រងតាមរយៈសុហ្វវែរ SPSS ។ បន្ទាប់មក ទិន្នន័យដើមអាចចូលប្រើប្រាស់បានដោយអង្គការលីកាដូ និងសមធម៌កម្ពុជា ដើម្បីផ្ទៀងផ្ទាត់ ក៏ដូចជាវិភាគបន្ថែម ។

ការព្រៀងរបាយការណ៍នេះ ត្រូវបានធ្វើឡើងចម្បងដោយអង្គការលីកាដូ និងអង្គការសមធម៌ ដោយផ្អែកលើទិន្នន័យដើមពីការស្ទង់មតិនិងការរកឃើញផ្សេងៗដោយក្រុមទីប្រឹក្សាក្រៅស្ថាប័ន។

## ការគណនាទំហំគំរូ (sample size)

ទំហំគំរូសម្រាប់ការសិក្សានេះ ត្រូវបានគណនាដោយប្រើប្រាស់រូបមន្តៈ $n_0 = p(១-p)(Z^២(\alpha/២))/e^២$ ខណៈដែល $n_0$ តំណាងឱ្យទំហំគំរូដើម $p$ តំណាងឱ្យការប៉ាន់ប្រមាណនៃសមាមាត្រចំនួនប្រជាជនទៅលើលក្ខណៈវិនិច្ឆ័យដែលបានសិក្សា $Z$ តំណាងឱ្យស្តង់ដារតម្លៃពិន្ទុ $Z$ នៃកម្រិតជឿទុកចិត្តបាន និង $e$ តំណាងឱ្យកំហុសគំរូរឹម (margin of error) នៃការប៉ាន់ស្មានដែលត្រូវការ ។ ជាមួយនឹង ៩៥% នៃកម្រិតជឿទុកចិត្តបាន $Z$ = ១,៩៦ និង ៥% នៃកំហុសគំរូរឹម $e$ = ០,០៥ ។ ដូចនេះទំហំគំរូដើមគឺត្រូវបានគណនាដូចខាងក្រោមនេះ៖

$$n_0 = ០,៥(១-០,៥)១,៩៦^២/០,០៥^២ \approx ៣៨៥$$

ការរចនាគំរូនេះ ត្រូវបានធ្វើឡើងដោយការជ្រើសរើសតាមបញ្ជីឈ្មោះ ជំនួសឱ្យគំរូផ្ទាល់ (សាកសួរពីផ្ទះមួយទៅផ្ទះមួយ) ហើយការវាស់វែងផលប៉ះពាល់នៃការរចនាគំរូ គួរតែត្រូវបានយកមកប្រើប្រាស់ក្នុងការគណនាទំហំគំរូ ។ តម្លៃនៃការវាស់វែងផលប៉ះពាល់នៃការរចនាគំរូ គឺខុសគ្នាពីប្រជាជនមួយក្រុមទៅប្រជាជនមួយក្រុមទៀត ប៉ុន្តែជាទូទៅ តម្លៃធម្មតារបស់វា គឺ ២ ។ ដូចនេះ ទំហំគំរូចុងក្រោយសម្រាប់ការសិក្សានេះ ត្រូវបានគណនាដូចខាងក្រោម៖

$$n = n_0 \times ២ = ៣៨៥ \times ២ \approx ៧៧០ \text{ ខ្នងផ្ទះ}$$

ការណ៍នេះបានធ្វើឱ្យកើនឡើងចំនួនគ្រោងទុកដល់ ៨០០ខ្នងផ្ទះ សរុបទាំងអស់ ។ ប៉ុន្តែដោយសារការស្ទង់មតិជាក់ស្តែង បានសម្ភាសប្រជាពលរដ្ឋត្រឹម ៧១៧ខ្នងផ្ទះ កម្រិតកំហុសគំរូរឹម ត្រូវបានកែប្រែទៅ ៥,១៧% ។

# អត្រាប្រជាជន និងទំហំគំរូ តាមស្រុកនីមួយៗ

| ឈ្មោះស្រុក | ចំនួនភូមិ | ចំនួនខ្នងផ្ទះ | ចំនួនកម្ម៏ | ចំនួនគំរូភូមិ | ចំនួនគំរូខ្នងផ្ទះ (គ្រោងទុក) | ចំនួនគំរូខ្នងផ្ទះ (ជាក់ស្តែង) |
|---|---|---|---|---|---|---|
| បរសេដ្ឋ | ២១៨ | ៣២.៩៣៨ | ៣២.៨៧៣ | ៨ | ១២៨ | ១១១ |
| ក្រុងច្បារមន | ៥៦ | ១០.៧៣៧ | ១០.៤៣៥ | ៣ | ៤៨ | ៤០ |
| គងពិសី | ២៥០ | ៣២.៧២០ | ៣៤.៤៨៥ | ៩ | ១៤៤ | ១៣២ |
| ឱរ៉ាល់ | ៧២ | ៨.៧២៩ | ៥.៣៩៦ | ២ | ៣២ | ២៦ |
| ឧដុង្គ | ២៥១ | ៣១.៨៣៤ | ៣៥.២៦៨ | ៩ | ១៤៤ | ១៣៤ |
| ភ្នំស្រួច | ១៥៤ | ២៤.០៨៨ | ២២.៧៩៧ | ៦ | ៩៦ | ៨៩ |
| សំរោងទង | ២៩៤ | ៤០.៥៣៨ | ៣៦.៧៨១ | ៩ | ១៤៤ | ១២១ |
| ថ្ពង | ៨៤ | ១៤.២៩៨ | ១៤.៤៧០ | ៤ | ៦៤ | ៦៤ |
| សរុប | ១.៣៧៩ | ១៩៥.៨៨២ | ១៩២.៥០៥ | ៥០ | ៨០០ | ៧១៧ |

*ស្រុកឧដុង្គ ត្រូវបានបែងចែកជា២ស្រុក (ឧដុង្គម៉ែជ័យ និងសាមគ្គីមុនីជ័យ) បន្ទាប់ពីការស្ទង់មតិ*



# ការអង្កេតប្រជាសាស្ត្រ

**អ្នកផ្តល់បទសម្ភាសន៍ (ចំនួនខ្នងផ្ទះ)**

**៧១៧**

**សមាជិកគ្រួសារក្នុងផ្ទះសរុប**

**៣.៤៥៧**

ការស្ទង់មតិនេះ ធ្វើឡើងទៅលើប្រជាពលរដ្ឋចំនួន ៧១៧ខ្នងផ្ទះ នៅគ្រប់ស្រុកក្នុងខេត្តកំពង់ស្ពឺ ដែលមានសមាជិកជាមធ្យម ៤,៨នាក់ រួមមាន មនុស្សពេញវ័យចំនួន ២.៣០១នាក់ (ប្រុស១.០៩២នាក់ និងស្រី១.២០៩នាក់) កុមារអាយុក្រោម១៨ឆ្នាំចំនួន ១.១៥៦នាក់ (ប្រុស៥៥៨នាក់ និងស្រី៥៩៨នាក់) ។ មនុស្សម្នាក់នៅតាមខ្នងផ្ទះនីមួយៗបានចូលរួមការស្ទង់មតិនេះ ដោយរួមមានអ្នកផ្តល់បទសម្ភាសន៍ ប្រុស៣៤១នាក់ (៤៧,៦%) និងស្រី៣៧៦នាក់ (៥២,៤%) ។ ក្នុងចំណោមនោះ មានតែ ១៣៤ខ្នងផ្ទះប៉ុណ្ណោះដែលស្ត្រីជាមេគ្រួសារ ខណៈដែល៥៦៨ខ្នងផ្ទះទៀតគឺបុរសជាមេគ្រួសារ (១៥ខ្នងផ្ទះទៀតមិនបានបញ្ជាក់ថាអ្នកណាជាមេគ្រួសារនោះទេ) ។

ការងារដែលធ្វើដោយមេគ្រួសារនៅក្នុងផ្ទះមានភាពខុសៗគ្នានៅក្នុងគំរូ ។ ភាគច្រើន ពួកគេជាកសិករ (២១%) កម្មករសំណង់ (១៨%) អ្នកលក់ដូរ (១៣%) និងកម្មកររោងចក្រ (១១%) ។

**អ្នកផ្តល់បទសម្ភាសន៍គិតតាមយេនឌ័រ**

**យេនឌ័រ**

**៥២%** ស្ត្រី

**៤៨%** បុរស



**មេគ្រួសារតាមខ្នងផ្ទះគិតតាមយេនឌ័រ**

**យេនឌ័រ**

**១៣៤** ស្ត្រី

**៥៦៨** បុរស

**អាយុអ្នកផ្តល់បទសម្ភាសន៍**

| | |
|---|---|
| ២១-២៩ ឆ្នាំ | ៧,៣% |
| ៣០-៣៩ ឆ្នាំ | ២៧,៣% |
| ៤០-៤៩ ឆ្នាំ | ២៩,៣% |
| ៥០-៥៩ ឆ្នាំ | ២២,៩% |
| ៦០+ ឆ្នាំ | ១៣,២% |

## មុខរបរភាគច្រើនរបស់មេគ្រួសារតាមខ្នងផ្ទះ

| | | | | |
|---|---|---|---|---|
| ២១% | ១៨% | ១៣% | ១១% | ៤% |
| កសិករ | កម្មករសំណង់ | អ្នកលក់ដូរ | កម្មកររោងចក្រ | កម្លាំងពលកម្ម |

## កម្រិតវប្បធម៌ខ្ពស់បំផុតរបស់មេគ្រួសារតាមខ្នងផ្ទះ




## ស្ថានភាពប័ណ្ណក្រីក្រតាមខ្នងផ្ទះ

**១៨%** នៃខ្នងផ្ទះសរុប ធ្លាប់ ឬកំពុងត្រូវបានរាជរដ្ឋាភិបាលបញ្ជាក់ថា ក្រីក្រ




ធ្លាប់មានប័ណ្ណក្រីក្រ | ប័ណ្ណក្រីក្រកម្រិត១ | ប័ណ្ណក្រីក្រកម្រិត២



**១.៧៤៥**

កម្ចីសរុបនៅ១០ឆ្នាំចុងក្រោយ

**១៣២**

"កម្ចីមិនផ្លូវការ" ពីអ្នកផ្ដល់កម្ចីដែលមិនបានចុះបញ្ជី

**៨២៩**

កម្ចី នៅបន្តបង់សង

**១.៦១៣**

កម្ចីផ្លូវការពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬធនាគារ

# បំណុលតាមខ្នងផ្ទះ

## ទិន្នន័យកម្ចី

សំណួរស្ទង់មតិ គ្រប់ដណ្ដប់លើខ្នងផ្ទះចំនួន ៧១៧ ដែលជាប់ជំពាក់កម្ចីឥណទានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬធនាគារនៅគ្រប់ស្រុកទាំងអស់ក្នុងខេត្តកំពង់ស្ពឺ ហើយបានសួរសំណួរពាក់ព័ន្ធនឹងកម្ចីចំនួន ១.៧៤៥ ដែលប្រជាពលរដ្ឋទាំងនេះបានខ្ចី ក្នុងរយៈពេល ១០ ឆ្នាំចុងក្រោយ ។[៩] ភាគច្រើននៃខ្នងផ្ទះទាំងនេះ (៨៨%) បានយកកម្ចីពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬធនាគារតែប៉ុណ្ណោះ ខណៈដែល ១២% ទៀត បានខ្ចីពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬធនាគារផង និងពីប្រភពមិនផ្លូវការផង ។[១០] ប្រហែលពាក់កណ្ដាលនៃកម្ចីទាំងនោះមិនទាន់បង់សងអស់វិញទេ (៨២៩កម្ចីដែលកំពុងជាប់ជំពាក់) ។

នៅក្នុង ៧០% នៃកម្ចីទាំងអស់ អ្នកផ្ដល់បទសម្ភាសន៍តាមខ្នងផ្ទះ បានបញ្ជាក់ថា ប្ដីប្រពន្ធបានខ្ចីកម្ចីរួមគ្នា ខណៈដែល ១៤,៦% បានបញ្ជាក់ថា "ប្រពន្ធ" ជាអ្នកខ្ចី ហើយ ៦% គឺប្ដីជាអ្នកខ្ចី ។ នៅសល់ ១០% ទៀតនៃអ្នកផ្ដល់បទសម្ភាសន៍បាននិយាយថា កម្ចីក្នុងគ្រួសាររបស់ពួកគេគឺជារបស់សមាជិកគ្រួសារផ្សេងទៀត ដូចជា ឪពុកឬម្ដាយ ឪពុកឬម្ដាយក្មេក ជីដូនឬជីតា ឬកូនពេញវ័យ ។

**ភាគច្រើននៃគ្រឹះស្ថានដែលផ្ដល់កម្ចី**




*កម្ចីចំនួន៧៩បន្ថែមទៀត ត្រូវបានចែកចាយ តាមរយៈគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុផ្សេងៗជាច្រើន ។*

[៩] ឥណទានខ្នាតតូចនៅកម្ពុជា គឺផ្ដល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (MFIs) គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ និងធនាគារពាណិជ្ជដែលពីមុនធ្លាប់ចុះឈ្មោះជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហើយនៅរក្សាផលបត្រមីក្រូហិរញ្ញវត្ថុ ។

[១០] "កម្ចីមិនផ្លូវការ" នៅក្នុងការស្ទង់មតិនេះ សំដៅលើកម្ចីឥណទានមួយ ដែលត្រូវបានផ្ដល់ឱ្យដោយប្រភពណាមួយ ក្រៅពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬធនាគារ ដែលបានចុះបញ្ជីជាមួយធនាគារជាតិនៃកម្ពុជា ។ សម្រាប់ព័ត៌មានបន្ថែម ចំពោះការប្រើប្រាស់ឥណទានមិនផ្លូវការនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា សូមមើលៈ

**១៤,២%**

នៃកម្ចី គឺចំណាយលើសេវាសុខភាព ឬការអប់រំ

**៣៤.៨%**

នៃកម្ចី គឺយកទៅសងបំណុលដែលមានស្រាប់ក្នុងឆ្នាំ២០២២

## ហេតុផលក្នុងការខ្ចី

ហេតុផលនៃការខ្ចីឥណទានត្រូវបានបង្ហាញថា ភាគច្រើននៃកម្ចីគឺមិនបានយកទៅប្រើប្រាស់ក្នុងសកម្មភាពដើម្បីបង្កើនប្រាក់ចំណូលទេ ។ កត្តាសេវាសុខាភិបាល (១២%) និងការអប់រំ (២,២%) ដែលជាហេតុផលក្នុងការខ្ចីបង្ហាញថា ការទទួលបានសេវាសង្គមមូលដ្ឋាននៅក្នុងប្រទេសកម្ពុជា ជារឿយៗ ទាមទារឱ្យត្រូវតែមានការខ្ចីប្រាក់ ឬជាប់ជំពាក់បំណុល ។

ហេតុផលនៃការខ្ចីដែលកើតមានញឹកញាប់ជាងគេ គឺដើម្បីសាងសង់ ឬជួសជុលផ្ទះ (៤០.៣%) ។ ការចាប់ផ្តើមអាជីវកម្ម (២១.៨%) ឬការធ្វើកសិកម្ម (៦%) មិនសូវកើតមាននោះទេ ។

### ហេតុផលក្នុងការខ្ចី




*ចម្លើយច្រើនជាងមួយត្រូវបានទទួលយក ។ ករណី "ផ្សេងទៀត" រួមបញ្ចូល "ការរៀបអាពាហ៍ពិពាហ៍ (៣៤)" និង "ទិញរថយន្ត (៣៨)" ។*




ក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ ច្រើនជាង ១/៥នៃកម្ចីដែលត្រូវបានចងក្រងនៅក្នុងការស្ទង់មតិ គឺដើម្បីបង់សងកម្ចីឥណទានផ្សេងទៀត (២០,២%) ដែលនេះបង្ហាញពីស្ថានភាពបំណុលដ៏គួរឱ្យព្រួយបារម្ភ ។ "ការខ្ចីដើម្បីបង់សងកម្ចីឥណទានផ្សេងទៀត" បានកើនឡើងរហូតនៅទសវត្សរ៍ចុងក្រោយនេះ បើតាមអ្នកផ្តល់បទសម្ភាសន៍ ។ វាគឺជាហេតុផលនៃការខ្ចីសម្រាប់កម្ចីត្រឹមតែ ៣,៤៥% ប៉ុណ្ណោះក្នុងឆ្នាំ២០១២ ប៉ុន្តែហេតុផលនេះបានកើនឡើងដល់ ២២,៧% នៃកម្ចី ក្នុងឆ្នាំ២០២០ និងបានកើនឡើងដល់ ៣៤,៨% ក្នុងឆ្នាំ២០២២ ដែលកំពុងឆ្លុះបញ្ចាំងពីទំហំកម្ចីធំជាងមុន និងការកើនឡើងនៃបន្ទុកបំណុលដ៏គួរឱ្យព្រួយបារម្ភ ។

## ភាពញឹកញាប់នៃការខ្ចី "ដើម្បីបង់សងកម្ចីផ្សេងទៀត"




*ភាគរយនៃកម្ចីទាំងអស់ដែលបានយកក្នុងឆ្នាំនោះ ។*

## "វដ្តនៃបំណុល" តួនាទីរបស់កម្ចីមិនផ្លូវការ ជាស្ពានចម្លងក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ឬធនាគារ"

អ្នកផ្តល់បទសម្ភាសន៍នៅក្នុងការស្ទង់មតិ បានលើកឡើងពី ការយកកម្ចីមិនផ្លូវការ (កម្ចីឥណទានពីគ្រឹះស្ថានហិរញ្ញវត្ថុដែលមិនបានចុះបញ្ជីត្រឹមត្រូវ) សម្រាប់ "សេវាសុខាភិបាល" (៥០%) និង"ការបង់សងកម្ចីឥណទានផ្សេងទៀត" (៤៥,៥%) ។ ករណីនេះស៊ីចង្វាក់គ្នានឹងឯកសារមុនៗរបស់អង្គការលីកាដូ និងអង្គការសមធម៌ ចំពោះការពឹងផ្អែកគ្នាទៅវិញទៅមករវាងវិស័យកម្ចីផ្លូវការ និងមិនផ្លូវការនៅកម្ពុជា ។

**សេវាសុខាភិបាល**

ក្នុងករណីមានបញ្ហាសុខភាពបន្ទាន់ ប្រជាពលរដ្ឋនៅក្នុងគ្រួសារតែងត្រូវការប្រាក់ឱ្យបានឆាប់ ពោលគឺនាំឱ្យពួកគេត្រូវទាក់ទងទៅអ្នកផ្តល់កម្ចីមិនផ្លូវការ ដែលមិនទាមទារឱ្យមានឯកសារច្រើន និងជារឿយៗអាចផ្តល់ប្រាក់បានលឿនជាងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬធនាគារ ។ ជាទូទៅ អ្នកផ្តល់ប្រាក់កម្ចីទាំងនេះ តែងកំណត់អត្រាការប្រាក់ខ្ពស់ជាងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬធនាគារ ដោយនៅចន្លោះពី ២% ទៅ ៣០% ក្នុងមួយខែនៅក្នុងករណីជាច្រើន បើប្រៀបធៀបទៅនឹងកម្ចីឥណទានផ្លូវការគឺ ១,៥% ក្នុងមួយខែ ។ ដោយសារតែអត្រាការប្រាក់ខ្ពស់នេះ អ្នកខ្ចីប្រាក់តែងស្វែងរកការដោះដូរបំណុលរបស់ពួកគេ ដោយការយកកម្ចីឥណទានពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬធនាគារ ដើម្បីបង់សងកម្ចីឯកជនទាំងនោះ ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ។

ជាទូទៅ កង្វះការផ្ទៀងផ្ទាត់ប្រាក់ចំណូល និងការផ្តល់កម្ចីផ្អែកទាំងស្រុងតែទៅលើតម្លៃនៃទ្រព្យធានា ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬធនាគារ បានធ្វើឱ្យដំណើរការនេះទៅជារឿងធម្មតា ដោយនៅក្នុងករណីជាច្រើនដែលចងក្រងដោយអង្គការលីកាដូ និងអង្គការសមធម៌ អ្នកខ្ចីបានប្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬធនាគារ ថា ពួកគេយកកម្ចីឥណទានដើម្បីសងកម្ចីមិនផ្លូវការ ។ វដ្តនៃបំណុលនេះ អនុញ្ញាតឱ្យអ្នកខ្ចី ប្រើប្រាស់អ្នកផ្តល់ប្រាក់កម្ចីមិនផ្លូវការ ជាស្ពានចម្លង ដើម្បីយកកម្ចីឥណទានពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬធនាគារ ដោយអាចទទួលបានប្រាក់ឆាប់ ប៉ុន្តែចុងក្រោយ ត្រូវយកកម្ចីឥណទានពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬធនាគារ ទៅចំណាយថ្លៃព្យាបាលជំងឺវិញ ។

**ការបង់សងឥណទានផ្សេងទៀត**

តាមរយៈការព្យាយាមរបស់ធនាគារជាតិនៃកម្ពុជា និងក្រុមហ៊ុនក្រេឌីត ប្យូរ៉ូ (ខេមបូឌា) ខូ អិលធីឌី (ស៊ីប៊ីស៊ី ឬCBC) "ការខ្ចីឆ្លង" (ការខ្ចីពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុច្រើន) ត្រូវបានកម្រិត នៅក្នុងប្រទេសកម្ពុជា បើប្រៀបធៀបទៅនឹងវិស័យមីក្រូហិរញ្ញវត្ថុផ្សេងទៀត ។ ជាពិសេស វាពិតជាកម្រឃើញមានគ្រឹះស្ថានផ្លូវការ ផ្តល់កម្ចីឥណទាន ដើម្បីបង់សងកម្ចីឥណទានផ្លូវការមួយទៀតណាស់ ។

ទោះបីជាយ៉ាងណា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬធនាគារ ជាទូទៅបានគេចចេញពីបទប្បញ្ញត្តិនេះ ដោយឱ្យអ្នកខ្ចីដោះដូរបំណុលជាមួយអ្នកផ្តល់ប្រាក់កម្ចីមិនផ្លូវការ ។ ដោយមានអ្នកខ្ចីម្នាក់យកប្រាក់កម្ចីមិនផ្លូវការ ដែលមិនបានចុះបញ្ជីជាមួយ ស៊ីប៊ីស៊ី ដើម្បីបង់សងកម្ចីផ្លូវការ អ្នកខ្ចីអាចបង់សងកម្ចីមីក្រូហិរញ្ញវត្ថុ ឬធនាគារដោយពេញ ដោយមិនចាំបាច់មានបញ្ហានៅក្នុងប្រព័ន្ធឃ្លាំមើលនោះទេ ។

បន្ទាប់មក (ម្តងទៀត ដោយសារកម្ចីមិនផ្លូវការមានអត្រាការប្រាក់ខ្ពស់) អ្នកខ្ចីភាគច្រើននឹងត្រូវយកកម្ចីពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬធនាគារ ដើម្បីបង់សងកម្ចីមិនផ្លូវការរបស់ពួកគេ មានន័យថាក៏ជាការខ្ចីពីអ្នកផ្តល់កម្ចីផ្លូវការដើម្បីសងទៅអ្នកផ្តល់កម្ចីផ្លូវការមួយទៀត ប៉ុន្តែប្រើប្រាស់អ្នកផ្តល់កម្ចីមិនផ្លូវការជាស្ពានចម្លង ដើម្បីបញ្ចៀសពីបញ្ហាផ្លូវច្បាប់ ។ អង្គការលីកាដូ និងអង្គការសមធម៌ បានចងក្រងករណីជាច្រើន ដែលមន្ត្រីឥណទាននៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬធនាគារ លើកទឹកចិត្ត ឬបង្ខំឱ្យអ្នកខ្ចីអនុវត្តបែបនេះ ដោយករណីខ្លះទៀត ក៏បានធ្វើគ្រប់មធ្យោបាយ ដើម្បីណែនាំអ្នកខ្ចីឱ្យអ្នកផ្តល់កម្ចីមិនផ្លូវការ និងរង់ចាំពួកគេរហូតទទួលបានប្រាក់កម្ចី ។

**$៩.០៧៣**

ទំហំកម្ចីជាមធ្យមក្នុងឆ្នាំ២០២២

**$៤.៣៨១**

ប្រាក់ចំណូលប្រចាំឆ្នាំជាមធ្យម នៅតំបន់ជនបទ ក្នុងឆ្នាំ២០២១

## ទំហំកម្ចីឥណទានជាមធ្យម

អ្នកផ្តល់បទសម្ភាសបានរៀបរាប់ថា ទំហំឥណទានជាមធ្យម បានកើនឡើងយ៉ាងរហ័ស នៅរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ ជាករណីដែលត្រូវបានបញ្ជាក់ដោយទិន្នន័យឧស្សាហកម្ម និងម៉ាក្រូសេដ្ឋកិច្ច ពីប្រភពផ្សេងៗ ។

យោងតាមរបាយការណ៍ឆ្នាំ២០១៦ របស់សន្ទស្សន៍មីក្រូហិរញ្ញវត្ថុនៃការទំនាក់ទំនង និងតិត្ថិភាពទីផ្សារ (MIMOSA) ទំហំកម្ចីនៅក្នុងប្រទេសកម្ពុជា បានកើនឡើងលឿនជាង ៤ដងនៃប្រាក់ចំណូល ពីឆ្នាំ២០០៤ ដល់ឆ្នាំ២០១៤ ។[១១] ការស្ទង់មតិរបស់យើងខ្ញុំបង្ហាញថា នៅក្នុងរយៈពេល៩ឆ្នាំ ចាប់តាំងពីការកើនឡើងនៃទំហំកម្ចី បានបន្តនាំមុខការកើនឡើងនៃប្រាក់ចំណូល ទំហំកម្ចីជាមធ្យមក្នុងឆ្នាំ២០១២ ត្រូវបានរាយការណ៍ថា ២.៥៦៨ដុល្លារ ដោយកើនឡើងចំនួន ២៥៣% ហើយនៅរយៈពេល១០ឆ្នាំបន្ទាប់គឺ ៩.០៧៣ដុល្លារ ក្នុងឆ្នាំ២០២២ ។ ទន្ទឹមគ្នានេះដែរ នៅរយៈពេលដូចគ្នានេះ ស្ថិតិរបស់រាជរដ្ឋាភិបាល បង្ហាញពីប្រាក់ចំណូល ប្រចាំឆ្នាំជាមធ្យម នៅតំបន់ជនបទ កើនឡើងពី ១.៦៤១ដុល្លារ ទៅ ៤.៣៨១ដុល្លារ មានន័យថាកើនឡើង ១៦៧% ដែលនេះតិចជាងកំណើននៃកម្ចីខ្លាំងណាស់ ។[១២] ការណ៍នេះ បណ្តាលឱ្យមនុស្សជាច្រើនជំពាក់បំណុល លើសឆ្ងាយពីប្រាក់ចំណូលប្រចាំឆ្នាំរបស់ពួកគេ ។

### ទំហំកម្ចីជាមធ្យម និងប្រាក់ចំណូលតាមខ្នងផ្ទះ




*ទិន្នន័យទំហំកម្ចីពីអ្នកផ្តល់បទសម្ភាសន៍ និងទិន្នន័យប្រាក់ចំណូលពីការស្ទង់មតិផ្ទៃកសង្គម និងសេដ្ឋកិច្ចនៅកម្ពុជា (CSES) ។*

[១១] កម្ពុជា៖ ទំហំឥណទាន និងការខ្ចីជាច្រើន" សន្ទស្សន៍មីក្រូហិរញ្ញវត្ថុនៃការទំនាក់ទំនង និងតិត្ថិភាពទីផ្សារ (MIMOSA) ចេញផ្សាយខែមិថុនា ឆ្នាំ២០១៦ ទំព័រទី៣ ។

[១២] "ការស្ទង់មតិអំពីសេដ្ឋកិច្ច និងសង្គម នៅកម្ពុជា" ដោយវិទ្យាស្ថានជាតិស្ថិតិ ដកស្រង់ពី៖ https://www.nis.gov.kh/index.php/km/14-cses/12-cambodia-socio-economic-survey-reports

៦៧%

ភាគរយជាមធ្យមនៃការចំណាយប្រចាំខែលើការបង់សងបំណុល

២៧.៣%

នៃខ្នងផ្ទះសរុបដែលចំណាយប្រាក់ចំណូលជាមធ្យមរបស់ពួកគេជាង ៧០% លើការបង់សងបំណុល

៩.៨%

នៃខ្នងផ្ទះសរុបដែលចំណាយប្រាក់ចំណូលជាមធ្យមរបស់ពួកគេលើសពី ១០០% លើការបង់សងបំណុល

## ប្រាក់ចំណូល និងការចំណាយលើការបង់សងបំណុល

គិតជាមធ្យម ការបង់សងបំណុលគឺមាន ៦៧% នៃការចំណាយសរុបប្រចាំខែរបស់ប្រជាពលរដ្ឋមួយខ្នងផ្ទះ ។ ការព្រួយបារម្ភយ៉ាងខ្លាំងនោះគឺ ២៧,៣% នៃចំនួនខ្នងផ្ទះទាំងនោះ បានលើកឡើងថា ពួកគេកំពុងចំណាយប្រាក់ចំណូលរបស់ពួកគេជាង៧០% ដើម្បីបង់សងបំណុល ជារៀងរាល់ខែ ។ ក្នុងនោះ ៩,៨% នៃចំនួនខ្នងផ្ទះសរុប កំពុងចំណាយប្រាក់ចំណូលរបស់ពួកគេ ជាង១០០% ទៅលើការបង់សងបំណុលប្រចាំខែ ដោយធ្វើឱ្យពួកគេក្លាយទៅជាប្រជាពលរដ្ឋដែលងាយរងគ្រោះយ៉ាងខ្លាំង ។

នេះគឺជាស្ថានភាពដ៏គួរឱ្យព្រួយបារម្ភដែលនាំឱ្យប្រជាពលរដ្ឋរាប់ម៉ឺននាក់ ស្ថិតក្នុងហានិភ័យនៃការបង្ខំឱ្យលក់ដី យកបំណុលបន្ថែម និងការលះបង់មួយចំនួនដូចជា ឱ្យកូនឈប់រៀន ឬកាត់បន្ថយអាហារបរិភោគ ដើម្បីសន្សំប្រាក់ទុកសងបំណុល ។ ករណីនេះ ក៏តំណាងឱ្យភាពបរាជ័យមួយផ្នែករបស់ស្ថាប័នផ្តល់កម្ចីផ្លូវការ ក្នុងការវាយតម្លៃឱ្យបានត្រឹមត្រូវពីប្រាក់ចំណូល និងលទ្ធភាពនៃការបង់សង មុនពេលសម្រេចផ្តល់កម្ចីឥណទានណាមួយ ។

ប្រសិនបើប្រៀបធៀបចំនួននៃការបង់សងបំណុល ទៅនឹងការចំណាយសរុប (ដោយមិនគិតពីប្រាក់ចំណូល ដូចខាងលើ) ចំនួនប្រជាជនដែលកំពុងចំណាយជាង ៧០% នៃការចំណាយសរុបរបស់ពួកគេ ក្នុងការបង់សងបំណុល នឹងកើនដល់ ៤៥% នៃចំនួនខ្នងផ្ទះសរុប ។ បញ្ហានេះ ក៏ប៉ះពាល់អ្នកខ្ចីប្រាក់ដែលក្រីក្រជាងគេ ដោយក្នុងចំណោមអ្នកផ្តល់បទសម្ភាសន៍ចំនួន ១២៩នាក់ ដែលបានលើកឡើងថា កំពុងមាន ឬធ្លាប់មានប័ណ្ណក្រីក្រ ៤៥,៧% នៃពួកគេ កំពុងចំណាយប្រាក់ ៧០% នៃការចំណាយសរុបប្រចាំខែរបស់ពួកគេទៅលើការបង់សងបំណុល ។

### សារៈសំខាន់នៃការកម្រិត ៧០%

ករណីដែលអ្នកខ្ចីប្រាក់ជាង ១/៤ ចំណាយប្រាក់ចំណូលរបស់ពួកគេជាង ៧០% លើការបង់សងបំណុលប្រចាំខែ មានន័យថាអ្នកផ្តល់ប្រាក់កម្ចីរបស់ពួកគេ បានរំលោភលើស្តង់ដារសកលនៃ Cerise+SPTF ។ ការកម្រិតដែលអាចជាបន្ទុកធ្ងន់ធ្ងរសម្រាប់អ្នកខ្ចីជាច្រើនស្រាប់ទៅហើយនោះ គឺកំពុងត្រូវបានដាក់បន្ទុកបន្ថែមដោយអ្នកផ្តល់កម្ចីជាច្រើនករណីនៅក្នុងប្រទេសកម្ពុជា ។

Cerise+SPTF គឺជាអង្គការសមាជិកភាពមួយ ដែលផ្តោតលើការកំណត់ស្តង់ដារ សម្រាប់អ្នកផ្តល់សេវាហិរញ្ញវត្ថុ ។ Cerise+SPTF ត្រូវបានផ្តល់ឱ្យនូវ "ភាពជាអ្នកគ្រប់គ្រងនៃស្តង់ដារការពារអតិថិជន" តាមរយៈការបិទបញ្ចប់យុទ្ធនាការវៃឆ្លាត (Smart Campaign) ក្នុងឆ្នាំ២០២០ ហើយគេហទំព័ររបស់ពួកគេបង្ហាញពីឃ្លោងឃ្លាមួយចំនួនដូចជា "ដំបូង កុំធ្វើឱ្យមានផលប៉ះពាល់ ។ ប៉ុន្តែក៏ត្រូវចាត់វិធានការចាំបាច់ផ្សេងទៀតដែរ" ។

នៅខែកុម្ភៈ ឆ្នាំ២០២២ Cerise+SPTF បានចេញផ្សាយការធ្វើបច្ចុប្បន្នភាពមួយស្តីពី "ស្តង់ដារសកលសម្រាប់ការគ្រប់គ្រងការអនុវត្តផ្នែកសង្គម និងបរិស្ថាន" ។ ក្នុងការវាស់ស្ទង់កិច្ចគាំពារអតិថិជននៃស្តង់ដារទាំងនេះ ស្តង់ដារ ៤.A.១.១.១ បានបញ្ជាក់ថាអ្នកខ្ចីប្រាក់ម្នាក់ មិនគួរចំណាយប្រាក់ចំណូលរបស់ពួកគេច្រើនជាង ៧០% ដើម្បីបង់សងបំណុលសរុបប្រចាំខែនោះទេ ។ គិតត្រឹមខែមិថុនា ឆ្នាំ២០២៣ គេហទំព័ររបស់ Cerise+SPTF បានចុះឈ្មោះស្ថាប័នផ្តល់កម្ចីមីក្រូហិរញ្ញវត្ថុនៅកម្ពុជាចំនួន៨ ដែលទទួលបាន "វិញ្ញាបនបត្រការពារអតិថិជនយ៉ាងសកម្ម" ។

ក្នុងចំណោមស្ថាប័នទាំង៨ មានស្ថាប័នចំនួន៦ ដែលត្រូវបានរាយការណ៍ថាជា ស្ថាប័នផ្តល់កម្ចីឥណទានដល់អ្នកផ្តល់បទសម្ភាសន៍នៅក្នុងការស្ទង់មតិនេះ ។ ៥ក្នុងចំណោម៦ស្ថាប័ននោះ មានអតិថិជនកំពុងជំពាក់បំណុលដែលបានលើកឡើងថាកំពុងប្រើប្រាស់ប្រាក់ចំណូលរបស់ពួកគេជាង ៧០% ទៅបង់សងបំណុលប្រចាំខែ ។

## តើអ្នកមានអារម្មណ៍ថា គ្រួសាររបស់អ្នកជាប់ជំពាក់បំណុលច្រើនពេកទេ?




ច្រើនជាង២/៣នៃអ្នកផ្តល់បទសម្ភាសន៍ បានយល់ស្របទាំងស្រុង (៣៤,៣%) ឬយល់ស្រប (៣៣,៣%) ថា គ្រួសាររបស់ពួកគេ ជាប់ជំពាក់បំណុលច្រើនពេក ។ មានតែ ៥,១% នៃអ្នកផ្តល់បទសម្ភាសន៍ប៉ុណ្ណោះដែលគិតថា ពួកគេមិនមានបំណុលច្រើនពេកទេ ។

---

## តើកម្ចីមីក្រូហិរញ្ញវត្ថុប៉ះពាល់ប្រាក់ចំណូលគ្រួសាររបស់អ្នកដូចម្តេច?




ភាគច្រើននៃអ្នកខ្ចី មានអារម្មណ៍ថា កម្ចីមីក្រូហិរញ្ញវត្ថុ ឬធនាគាររបស់ពួកគេ មិនបានប៉ះពាល់ដល់ប្រាក់ចំណូលរបស់ពួកគេ (៤៥,៥%) ឬធ្វើឱ្យប្រសើរឡើងនូវប្រាក់ចំណូលរបស់ពួកគេ (៣៨,៦%) ខណៈដែល មួយចំនួនតូចមានអារម្មណ៍ថា កម្ចីមីក្រូហិរញ្ញវត្ថុ ឬធនាគាររបស់ពួកគេ បានធ្វើឱ្យធ្លាក់ចុះនូវប្រាក់ចំណូលក្នុងគ្រួសាររបស់ពួកគេ (១៥,៩%) ។

**៩២,២%**

នៃខ្នងផ្ទះសរុប ត្រូវបានទាមទារឱ្យដាក់ប័ណ្ណកម្មសិទ្ធិដីធ្លីជាទ្រព្យធានាយ៉ាងតិចមួយ

**០,៣%**

នៃខ្នងផ្ទះសរុប ត្រូវបានទាមទារឱ្យផ្តល់ផែនការអាជីវកម្ម ដើម្បីទទួលបានកម្ចីមួយ

## ទ្រព្យធានា និងការទទួលបានកម្ចី

ប័ណ្ណកម្មសិទ្ធិដីធ្លី គឺជាតម្រូវការសំខាន់ជាងគេក្នុងការទទួលបានកម្ចីឥណទាននៅកម្ពុជា ។ ជាង ៩២% នៃប្រជាពលរដ្ឋតាមខ្នងផ្ទះ (៦៦១ខ្នងផ្ទះ) ត្រូវបានតម្រូវឱ្យដាក់បញ្ចាំប័ណ្ណកម្មសិទ្ធិដីធ្លី ដើម្បីធានាក្នុងការទទួលបានកម្ចីមីក្រូហិរញ្ញវត្ថុ ឬធនាគារ ។

ត្រឹមតែ ៥០% ប៉ុណ្ណោះ ដែលត្រូវបានតម្រូវឱ្យផ្តល់ឯកសារបញ្ជាក់ពីប្រាក់ចំណូលរបស់ពួកគេ ខណៈដែល ២០% បានរាយការណ៍ថា ពួកគេក៏ត្រូវផ្តល់ឯកសារបញ្ជាក់ប្រាក់ចំណូលពីកូន ឬសមាជិកគ្រួសារផ្សេងទៀត ។

ប្រជាពលរដ្ឋចំនួន ៣០៩ខ្នងផ្ទះ ត្រូវដាក់ធានាប្លង់ទន់យ៉ាងតិចមួយ (៤៣.៣%) និង៣៥៩ខ្នងផ្ទះទៀត ដាក់ធានាប្លង់រឹងយ៉ាងតិចមួយ (៥០,៣%) ដើម្បីយកកម្ចីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬធនាគារ ។[១៣] ខ្នងផ្ទះចំនួន៧ ត្រូវបានទាមទារឱ្យដាក់ធានាទាំងប្លង់រឹង និងប្លង់ទន់ ដោយនេះមានន័យថា ខ្នងផ្ទះចំនួន៦៦១ ត្រូវបានទាមទារឱ្យដាក់ធានានូវប្លង់ដីយ៉ាងតិចមួយ សម្រាប់កម្ចីឥណទានខ្នាតតូច (៩២,២% នៃអ្នកដែលបានផ្តល់បទសម្ភាសន៍សរុប) ។

លើសពីការដាក់ទ្រព្យធានា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជាញឹកញាប់ក៏បានទាមទារឱ្យមានអ្នកធានា (៤៧,៥%) ឬហត្ថលេខាពីអាជ្ញាធរមូលដ្ឋាន (៥៥,២%) ដើម្បីអាចទទួលបានកម្ចី ។ អ្នកផ្តល់បទសម្ភាសន៍ត្រឹមតែ២នាក់ប៉ុណ្ណោះក្នុងចំណោម ៧១៤នាក់ ដែលបានលើកឡើងថា ពួកគេត្រូវបានតម្រូវឱ្យធ្វើផែនការអាជីវកម្ម ដើម្បីទទួលបានកម្ចីឥណទាន ។

### ឯកសារតម្រូវ ដើម្បីទទួលបានឥណទានពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬធនាគារ

| ឯកសារដែលតម្រូវ ដើម្បីទទួលបានឥណទាន | ចំនួន | ភាគរយ |
|---|---|---|
| ហត្ថលេខាពីអាជ្ញាធរ | ៣៩៤ | ៥៥.២% |
| ប័ណ្ណកម្មសិទ្ធិដីធ្លី (ប្លង់រឹង) | ៣៥៩ | ៥០.៣% |
| ភស្តុតាងបញ្ជាក់ប្រាក់ចំណូលពីប្តីឬប្រពន្ធ | ៣៥៧ | ៥០.០% |
| អ្នកធានា | ៣៣៩ | ៤៧.៥% |
| ប័ណ្ណកម្មសិទ្ធិដីធ្លី (ប្លង់ទន់) | ៣០៩ | ៤៣.៣% |
| ភស្តុតាងបញ្ជាក់ប្រាក់ចំណូលពីកូនឬគ្រួសារផ្សេងទៀត | ១៤៧ | ២០.៦% |
| សាក្សី | ៧៩ | ១១.១% |
| បញ្ជីទ្រព្យសម្បត្តិផ្សេងទៀត | ៤ | ០.៦% |
| ផែនការអាជីវកម្ម | ២ | ០.៣% |
| ផ្សេងទៀត | ៩ | ១.៣% |

*ចម្លើយលើសពីមួយត្រូវបានទទួលយក ។ ប្រជាពលរដ្ឋចំនួន៧ខ្នងផ្ទះ បានដាក់ប្លង់រឹង និងប្លង់ទុន ជាទ្រព្យធានា ។*

[១៣] ប្លង់ "រឹង" ត្រូវបានទទួលស្គាល់ថានៅថ្នាក់ជាតិ ខណៈដែលប្លង់ "ទន់" ត្រូវបានទទួលស្គាល់នៅថ្នាក់ក្រោមជាតិ ។ ប្លង់ទាំងពីរ ជាទូទៅ ត្រូវបានទទួលយកជាភស្តុតាងបញ្ជាក់ពីកម្មសិទ្ធិដីធ្លីនៅក្នុងប្រទេសកម្ពុជា និងធ្វើជាទ្រព្យធានា សម្រាប់កម្ចីមីក្រូហិរញ្ញវត្ថុ ដូចបានបញ្ជាក់ក្នុងរបាយការណ៍ស្តីពី "ការធ្វើឱ្យខូចខាតទ្រព្យដាក់បញ្ចាំ៖ ការបាត់បង់ដីធ្លី និងការរំលោភបំពានក្នុងវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា" ដកស្រង់ពី៖ https://www.mficambodia.com/reports/Report-CollateralDamage-2019-km.pdf



**៩,៧%**

**អ្នកផ្តល់បទសម្ភាសន៍ មិនបានអាន កិច្ចសន្យា ហើយមន្ត្រីឥណទានមិនបាន ពន្យល់ពីកិច្ចសន្យានោះទៅកាន់ពួកគេ**

## ការអាន និងឈ្វេងយល់ពីកិច្ចសន្យា

អ្នកផ្តល់បទសម្ភាសន៍ត្រឹម ៣៦% ប៉ុណ្ណោះ ក្នុងចំណោម ៧១៣នាក់ ដែលបានលើកឡើងថា បានអានកិច្ចសន្យាដោយខ្លួនឯង ។ នេះអាច ជាការឆ្លុះបញ្ចាំង ពីអត្រាទាបនៃអក្ខរកម្ម និងភាពស្មុគស្មាញ ក៏ដូចជារយៈពេលមធ្យមនៃកិច្ចសន្យាកម្ចីមីក្រូហិរញ្ញវត្ថុ ។

ទោះបីជាយ៉ាងណា មន្ត្រីឥណទានជារឿយៗបានផ្តល់សេចក្តីសង្ខេបនៃកិច្ចសន្យា (៨៩%) ទោះបីជាការស្ទង់មតិមិនបានសួរពីព័ត៌មានលម្អិតនៅក្នុងនោះក៏ដោយ ។ អ្នកផ្តល់បទសម្ភាសន៍ ៦៩នាក់ ស្មើនឹង ៩,៧% បានរៀបរាប់ថា ពួកគេមិនបានអានកិច្ចសន្យា ហើយមិនទទួលបានការពន្យល់ពីមន្ត្រីឥណទានទេ មានន័យថាពួកគេមិនដឹងពីអ្វីដែលបានសរសេរនៅក្នុងឯកសារកម្ចីឥណទាននោះតែម្តង ។

### អ្នកខ្ចីដែលបានអានកិច្ចសន្យា




---

[១៤] ផ្អែកលើកិច្ចសម្ភាសន៍រាប់រយកន្លងមកជាមួយអ្នកខ្ចីប្រាក់ ដែលធ្វើឡើងដោយអង្គការលីកាដូ និងអង្គការសមធម៌កម្ពុជា សេចក្តីសង្ខេបនេះ ភាគច្រើនរួមបញ្ចូលព័ត៌មានហិរញ្ញវត្ថុបឋម (ដូចជាចំនួនកម្ចី រយៈពេលនៃកម្ចី អត្រាការប្រាក់ និងកាលវិភាគបង់សង) ប៉ុន្តែខ្វះព័ត៌មានពាក់ព័ន្ធនឹងទ្រព្យធានា ការយឹតយ៉ាវក្នុងការបង់សង ឬការរឹបអូស ។

**៤៤,២%**

អ្នកខ្ចីប្រាក់ ដែលជឿថាដីធ្លីរបស់ពួកគេនឹងត្រូវរឹបអូសប្រសិនបើខកខានបង់សង

**១,៤%**

អ្នកផ្តល់បទសម្ភាសន៍ ដែលបានគិតថា ដីធ្លីរបស់ពួកគេ អាចនឹងត្រូវរឹបអូសតាមរយៈដំណើការតុលាការក្នុងករណីខកខានបង់សង

ការឆ្លើយតបទៅនឹងសំណួរផ្សេងទៀត បញ្ជាក់ថា ទោះបីជាមន្ត្រីឥណទាន ឬអ្នកខ្ចី បានអានសេចក្តីសង្ខេបនៃកិច្ចសន្យា និងព័ត៌មានសំខាន់ៗដូចជា ដំណើរការរឹបអូសតាមផ្លូវច្បាប់ក៏ដោយ ក៏ជាក់ស្តែងមិនត្រូវបានឃើញថា អាចធ្វើទៅរួចពិតប្រាកដនៅក្នុងប្រទេសកម្ពុជាទេ ។

ជាឧទាហរណ៍ ទោះបីជាអត្រាខ្ពស់នៃការដាក់ទ្រព្យធានា អ្នកខ្ចីប្រាក់ជាងពាក់កណ្តាលមិនបានគិតថា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬធនាគារ អាចនឹងរឹបអូសទ្រព្យធានារបស់ពួកគេទេប្រសិនបើពួកគេគ្មានលទ្ធភាពសង ។

លើសពីនេះទៀត ភាគច្រើននៃ ៤៤,២% នៃអ្នកខ្ចីប្រាក់ ដែលគិតថា អ្នកផ្តល់កម្ចីរបស់ពួកគេ អាចរឹបអូសដីរបស់ពួកគេ ក្នុងករណីដែលពួកគេមិនអាចបង់សងវិញ គិតថា ដំណើរការនេះមិនបានកើតឡើងតាមអ្វីដែលគួរតែធ្វើ ផ្អែកតាមច្បាប់កម្ពុជានោះទេ ។

ត្រឹមតែ៣,២%នៃពួកគេ បានគិតថា ការខកខានបង់សងអាចនឹងពាក់ព័ន្ធតុលាការ ដូចអ្វីដែលមានចែងនៅក្នុងច្បាប់ស្តីភូមិបាល ឆ្នាំ២០០១ និងក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ (១,៤%នៃអ្នកផ្តល់បទសម្ភាសន៍ទាំងអស់) ។ ដូចគ្នានេះដែរ ៤០% នៃពួកគេ គិតថា ដំណើរការនេះអាចនឹងជាប់ពាក់ព័ន្ធជាមួយអាជ្ញាធរមូលដ្ឋាន ហើយ ៣២,៥% គិតថា មន្ត្រីឥណទាន អាចនឹងរឹបអូសទ្រព្យធានារបស់ពួកគេ និង ៣៤,១% មិនដឹងថា អាចនឹងមានអ្វីកើតឡើង ។

ករណីនេះ ឆ្លុះបញ្ចាំងពីការអនុវត្តយ៉ាងទូលំទូលាយនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬធនាគារនៅកម្ពុជា ក្នុងការបញ្ចៀសដំណើរការរឹបអូស ហើយអនុវត្តការដាក់សម្ពាធទៅលើអ្នកខ្ចីប្រាក់ ឱ្យបង្ខំចិត្តដាក់លក់ទ្រព្យសម្បត្តិ ដើម្បីសងបំណុលដោយគ្មានការសម្រេចពីតុលាការ ។ ម្តងទៀត ការរកឃើញនេះ ស៊ីគ្នានឹងរបាយការណ៍គុណភាពជាច្រើនរបស់អង្គការមិនមែនរដ្ឋាភិបាល សហជីព និងសហគមន៍ នៅក្នុងប្រទេសកម្ពុជា ដែលបានធ្វើឡើងតាំងពីឆ្នាំ២០១៩ ដោយបានរៀបរាប់លម្អិតពីវិធីសាស្ត្របង្ខិតបង្ខំ នៅក្រៅប្រព័ន្ធតុលាការ ។

## តើដីធ្លីរបស់អ្នកនឹងត្រូវរឹបអូសដូចម្តេចដែរប្រសិនបើខកខានបង់សង?




*៣១៧ ខ្ទង់ផ្ទះជឿថា ដីធ្លីរបស់ពួកគេនឹងត្រូវរឹបអូសក្នុងករណីខកខានការបង់សង ។*




# ផលប៉ះពាល់ និង ការរំលោភសិទ្ធិមនុស្ស

**៦,១%**

នៃខ្នងផ្ទះសរុប បានលើកឡើងថា បានលក់ដី ដើម្បីសងបំណុលមីក្រូហិរញ្ញវត្ថុ ឬធនាគារ

## ការលក់ដី និងទ្រព្យសម្បត្តិដោយសារជំពាក់បំណុល

ក្នុងចំណោម ៧១៧ខ្នងផ្ទះ ដែលបានធ្វើបទសម្ភាសន៍ ៤៨ខ្នងផ្ទះ (៦,៧%) បានរាយការណ៍ពីការលក់ដី ដើម្បីសងបំណុល ហើយ ៤៤ខ្នងផ្ទះ បានរាយការណ៍ពីការលក់ដី ដើម្បីបង់សងបំណុលមីក្រូហិរញ្ញវត្ថុ ឬធនាគារ (៦,១%នៃអ្នកផ្តល់បទសម្ភាសន៍ទាំងអស់) ខណៈដែល ៤ខ្នងផ្ទះ ទៀតលក់ដីដើម្បីសងបំណុលឯកជន ។

នេះគឺស្រដៀង ទៅនឹងការរកឃើញនៃរបាយការណ៍របស់ INEFដែរ ដែលបានរកឃើញថា ៦,២% នៃគំរូរបស់ពួកគេបានលក់ដី ដើម្បីសងបំណុលឥណទានខ្នាតតូច ។[១៥] របាយការណ៍ INEF បានរកឃើញថា នៅទូទាំងប្រទេសកម្ពុជា ខ្នងផ្ទះប្រមាណជា ១៦៧,០០០ ត្រូវបានបាត់បង់ស្រដៀងគ្នា តាមរយៈការលក់ដីដោយសារបញ្ហាបំណុលនេះ ។

បន្ទុកបំណុលដ៏ធ្ងន់ធ្ងរ ដែលកំពុងធ្វើឱ្យប៉ះពាល់ដល់ប្រជាពលរដ្ឋខ្មែរជាច្រើនគ្រួសារ បង្ហាញថា តួលេខដ៏អាក្រក់នេះ នឹងបន្តកើនឡើង លុះត្រាតែមានបទប្បញ្ញត្តិស្តីពីការអនុគ្រោះបំណុល និងការប្រគល់ប័ណ្ណកម្មសិទ្ធិដីធ្លីឱ្យទៅអ្នកខ្ចីប្រាក់វិញ ។

៤ ក្នុងចំណោម ៤៨ករណីនៃការលក់ដី ត្រូវបានធ្វើឡើង ដើម្បីបង់សងបំណុលមិនផ្លូវការ ។ ក្នុងនោះមាន២ករណី ដែលកម្ចីមិនផ្លូវការត្រូវបានធ្វើឡើង ដើម្បីយកទៅសងកម្ចីឥណទានផ្លូវ

[១៥] របាយការណ៍របស់ វិទ្យាស្ថានសម្រាប់ការអភិវឌ្ឍន៍ និងសន្តិភាព (INEF) ស្តីពី "មីក្រូ" ហិរញ្ញវត្ថុនៅកម្ពុជា៖ ការអភិវឌ្ឍន៍ បញ្ហាប្រឈម និងអនុសាសន៍" ទំព័រទី៧៣ ដកស្រង់ពី៖ https://geswiss-ude.de/wp-content/uploads/2023/01/AVE-30-b-micro-finance-in-cambodia.pdf

**២៥%**

**នៃខ្នងផ្ទះសរុបដែលបានលក់ដី គឺជាអ្នកដែលធ្លាប់មាន ឬកំពុងមានប័ណ្ណក្រីក្រ**

ការជាមួយមីក្រូហិរញ្ញវត្ថុ ឬធនាគារ ដែលនេះបង្ហាញដោយប្រយោលថា មូលហេតុនៃការលក់ដីទាំងនេះគឺដោយសារ កម្ចីឥណទានផ្លូវការ ។ ចំណែកឯករណី២ទៀត អ្នកខ្ចីប្រាក់ក៏មានប្រវត្តិយកកម្ចីមីក្រូហិរញ្ញវត្ថុ ឬធនាគារផង និងកម្ចីមិនផ្លូវការផង ប៉ុន្តែភាពមានកម្រិតនៃការស្ទង់មតិ (ដូចជាអ្នកផ្តល់បទសម្ភាសន៍មិនចាំកាលបរិច្ឆេទកម្ចី) បានធ្វើឱ្យមានផលវិបាកក្នុងការវាយតម្លៃពីហេតុផលដែលការលក់ដីទាំងនោះ អាចកើតមានឡើង ។

២៥% នៃចំនួនខ្នងផ្ទះដែលបានលក់ដី គឺជាប្រជាពលរដ្ឋដែលមានប័ណ្ណក្រីក្រ ឬក៏ធ្លាប់ត្រូវបានកំណត់ថា ជាជនក្រីក្រ ទោះបីជាប្រជាពលរដ្ឋតាមខ្នងផ្ទះទាំងនោះ មានតែ ១៧,៥% នៃគំរូសរុបក៏ដោយ ។

## ការលក់ដី ដោយសារការជាប់ជំពាក់បំណុល ពីសំណាក់អ្នកដែលមានប័ណ្ណក្រីក្រ




ក្នុងចំណោមអ្នកផ្តល់កម្ចីដ៏ច្រើន (ធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលមានច្រើនជាង ១% នៃកម្ចីទាំងអស់ក្នុងការស្ទង់មតិ) គ្រឹះស្ថានទាំងអស់ មានអតិថិជនរាយការណ៍ពីការលក់ដី ដើម្បីសងគ្រឹះស្ថានទាំងនោះ ។ នេះបញ្ជាក់ពី មូលហេតុដ៏ទូលំទូលាយ និងជាលក្ខណៈប្រព័ន្ធនៃការលក់ដីដោយសារបញ្ហាបំណុល ដែលមិនត្រូវបានចាត់ទុកជា "បុគ្គលប្រព្រឹត្តអាក្រក់" ប៉ុន្តែគឺជាសារៈសំខាន់នៃវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជាទៅវិញ ។

## ការលក់ដី ដោយសារការជាប់ជំពាក់បំណុល បែងចែកតាមស្ថាប័ន ឬអ្នកផ្តល់កម្ចីនីមួយៗ

| ស្ថាប័ន ឬអ្នកផ្តល់កម្ចី | ដីចំការ | ដីលំនៅឋាន | សរុប |
|---|---|---|---|
| ប្រាសាក់ | ៩ | ៥ | ១៤ |
| អេស៊ីលីដា | ៨ | ១ | ៩ |
| អម្រឹត | ៧ | | ៧ |
| ដាប់ប៊ែលយូ ប៊ី ហ្វាយនែន | ៤ | ១ | ៥ |
| កម្ចីក្រៅផ្លូវការ | ៤ | | ៤ |
| អេអឹមខេ | ៣ | ១ | ៤ |
| ស្ថាបនា | ៣ | | ៣ |
| អិលអូអិលស៊ី | ៣ | | ៣ |
| ផ្សេងទៀត | ២ | ១ | ៣ |
| ហត្ថា | ១ | ១ | ២ |
| សរុប | ៤០ | ១០ | ៥៤ |

*ខ្នងផ្ទះមួយចំនួន បានលក់ដីដើម្បីបង់សងអ្នកផ្តល់កម្ចីជាច្រើន ។*



**១១,៩%**

នៃខ្នងផ្ទះសរុប បានលក់ទ្រព្យសម្បត្តិ ដើម្បីបង់សងកម្ចីមីក្រូហិរញ្ញវត្ថុ ឬធនាគារ

លើសពីការលក់ដី អ្នកខ្ចីប្រាក់ជាច្រើនត្រូវលក់ទ្រព្យសម្បត្តិ ឬសន្សំប្រាក់ ដូចជាគ្រឿងមានតម្លៃ ដើម្បីសងបំណុលវិញ ។ ការលក់ទាំងនេះ ជារឿយៗ ធ្វើឱ្យបាត់បង់ទ្រព្យសម្បត្តិដែលប្រើប្រាស់នៅក្នុងគ្រួសារសម្រាប់រកប្រាក់ចំណូលដូចជា ម៉ូតូ និងសត្វចិញ្ចឹម ឬកាត់បន្ថយការសន្សំនៅក្នុងគ្រួសារ (ជាទូទៅជាគ្រឿងអលង្ការ) ។ ការណ៍នេះ ធ្វើឱ្យធ្លាក់ចុះនៃសមត្ថភាព និងស្ថិរភាពសេដ្ឋកិច្ចរយៈពេលវែងរបស់គ្រួសារដើម្បីឆ្លើយតបទៅនឹងវិបត្តិហិរញ្ញវត្ថុនៅថ្ងៃអនាគត។

ក្នុងចំណោម ៧១៧ខ្នងផ្ទះ មាន៨៥ខ្នងផ្ទះ បានលក់ទ្រព្យសម្បត្តិ ដើម្បីសងបំណុល (១១,៩%) ។

## តើទ្រព្យសម្បត្តិអ្វីដែលអ្នកបានលក់ ដើម្បីបង់សងកម្ចីមីក្រូហិរញ្ញវត្ថុ ឬធនាគារ?




*៨៥ខ្នងផ្ទះ បានលក់ទ្រព្យសម្បត្តិ ប៉ុន្តែផ្ទះខ្លះបានលក់ទ្រព្យសម្បត្តិជាច្រើនប្រភេទ ដូចនេះតួលេខតារាងខាងលើ មិនស្មើចំនួន៨៥ទេ ។*



នៅក្នុងការស្ទង់មតិនេះមានកុមារ៖

**១.១៥៦នាក់**

ជាសមាជិកគ្រួសារតាមខ្នងផ្ទះសរុប មានអាយុក្រោម ១៨ឆ្នាំ

**៩០នាក់**

រកប្រាក់ ដើម្បីជួយផ្គត់ផ្គង់គ្រួសារ

**៥១នាក់**

រកប្រាក់ ដើម្បីតែយកទៅសងកម្ចីមីក្រូហិរញ្ញវត្ថុ ឬធនាគារ

**៨៧នាក់**

បានបោះបង់ការសិក្សា (សម្រាប់ហេតុផលណាមួយ)

**៤១នាក់**

បានបោះបង់ការសិក្សា ដោយសារតែកម្ចីមីក្រូហិរញ្ញវត្ថុ ឬធនាគារ

## ផលប៉ះពាល់លើកុមារ៖ ពលកម្មកុមារ និងការបោះបង់ការសិក្សា

ពេលខ្លះ គ្រួសារជាច្រើន ដែលកំពុងប្រឈមនឹងបញ្ហាលំបាកក្នុងការបង់សងបំណុល បានឱ្យកូនរបស់ពួកគេឈប់រៀន ដើម្បីជៀសវាងពីការបង់ថ្លៃសាលា ។[១៦] កុមារអាយុក្រោម ១៨ឆ្នាំ ក៏ធ្វើការដើម្បីជួយឪពុកម្តាយរបស់ពួកគេ សងបំណុលដែរ ។ ផលប៉ះពាល់ទាំងពីរនេះ កើតឡើងជាមួយគ្នាជារឿយៗ ។

ពលកម្មកុមារ ដែលត្រូវបានឱ្យនិយមន័យយ៉ាងទូលំទូលាយថាជាពលកម្មដែលរំខានដល់ការអប់រំរបស់កុមារ ជញ្ជក់ផលប្រយោជន៍ គ្រោះថ្នាក់ ឬមានផលប៉ះពាល់អវិជ្ជមានដល់ការលូតលាស់ផ្នែករូបរាងកាយ សង្គម ឬផ្លូវចិត្តរបស់ពួកគេ មិនមែនបណ្តាលមកពីបំណុលទាំងស្រុងនោះទេ ទោះបីជារឿងនេះជារឿយៗកាន់តែធ្ងន់ធ្ងរឡើងៗដោយសារសម្ពាធកម្ចីហិរញ្ញវត្ថុរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬធនាគារដែលមានទំហំធំជាងឆ្ងាយពីប្រាក់ចំណូលគ្រួសារ ។

កុមារ ៤១នាក់ ដែលឈប់រៀន ដោយសារកម្ចីមីក្រូហិរញ្ញវត្ថុ ឬធនាគារ គឺស្ថិតក្នុងចំណោមប្រជាពលរដ្ឋ ២១ខ្នងផ្ទះ (២,៩% នៃខ្នងផ្ទះសរុប) ។ កុមារសរុប ៨៧នាក់ នៅក្នុងការស្ទង់មតិ បានឈប់រៀន ដូច្នេះតួលេខកុមារ ៤១នាក់ ដែលបានឈប់រៀនដោយសារបំណុលមីក្រូហិរញ្ញវត្ថុ ឬធនាគារ បង្ហាញថា កម្ចីមីក្រូហិរញ្ញវត្ថុ ឬធនាគារ គឺស្មើនឹងតួលេខកុមារឈប់រៀនជិត២ដង ក្នុងចំណោមគ្រួសារតាមខ្នងផ្ទះដែលជំពាក់កម្ចីឥណទានខ្នាតតូចផ្លូវការ ។

លើសពីនេះ កុមារស្ទើរតែទាំងអស់ ដែលកំពុងរកប្រាក់ចំណូល ដើម្បីជួយបង់សងបំណុល (៥១នាក់) ហើយក៏បានឈប់រៀនដែរ (៤៩នាក់) ទាំងដោយសារបំណុល (៤១នាក់) និងហេតុផលផ្សេងទៀត (៨នាក់) ។ អាយុរបស់កុមារ ៥១នាក់ ដែលបច្ចុប្បន្នកំពុងជួយសងបំណុលមីក្រូហិរញ្ញវត្ថុ ឬធនាគារ គឺនៅចន្លោះពី១០ឆ្នាំ ទៅ ១៧ឆ្នាំ ។

---

[១៦] "ថ្លៃចំណាយមិនផ្លូវការ" នៅក្នុងប្រព័ន្ធអប់រំសាធារណៈដែលឥតគិតថ្លៃ នៅក្នុងប្រទេសកម្ពុជា បានកើតឡើងរាប់ទសវត្សរ៍មកហើយ ហើយកម្រៃអាចលើសពី ១០០ដុល្លារក្នុងមួយខែ សម្រាប់សិស្សអនុវិទ្យាល័យ ។ សម្រាប់ព័ត៌មានបន្ថែម សូមមើល៖ ការទប់ស្កាត់ថ្លៃចំណាយមិនផ្លូវការ និងការបង្រៀនឯកជន នៃការអប់រំមូលដ្ឋាននៅក្នុងប្រទេសកម្ពុជា" ដោយកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) ចេញផ្សាយឆ្នាំ២០១៤ ដកស្រង់ពី៖ https://ticambodia.org/library/wp-content/files_mf/1437033856CurbingPrivateTutoringInformalFeesinCambodiaBasicEducation.pdf

ប្រភេទពលកម្មដែលកុមារទាំងនេះធ្វើ បង្ហាញថា ក្រៅពីការរំខានដល់ការអប់រំរបស់កុមារ ភាគច្រើននៃសកម្មភាពសេដ្ឋកិច្ចនោះ គឺទំនងជា មិនបានកំណត់អាយុត្រឹមត្រូវ និងមានគ្រោះថ្នាក់ ឬការគំរាមកំហែងដល់ការលូតលាស់ផ្នែកសង្គម សុខភាព រូបរាងកាយ ឬផ្លូវចិត្ត របស់ពួកគេ ។

ដូចគ្នានឹងការលក់ដីដោយបង្ខំដែរ ការប្រើប្រាស់ពលកម្មកុមារក្នុងការបង់សងបំណុលគឺ ត្រូវបានប្រើប្រាស់ដោយអ្នកខ្ចីប្រាក់របស់គ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗគ្នានៅក្នុងការស្ទង់មតិនេះ ដោយម្តងទៀតឆ្លុះបញ្ចាំងថា នេះមិនមែនជាបញ្ហាសម្រាប់អ្នកផ្តល់កម្ចីឥណទានមួយទេ ប៉ុន្តែជាបញ្ហាជាប្រព័ន្ធនៅទូទាំងវិស័យនេះតែម្តង ។

## អាយុរបស់កុមារ ដែលធ្វើការរកប្រាក់ ដើម្បីសងកម្ចីមីក្រូហិរញ្ញវត្ថុ ឬធនាគារ




## មុខរបររបស់កុមារដែលធ្វើការរកប្រាក់ ដើម្បីសងកម្ចីមីក្រូហិរញ្ញវត្ថុ ឬធនាគារ




*កុមារ២នាក់ដែលបានកំណត់ក្នុងប្រភេទ "ផ្សេងទៀត" មិនបានឈប់រៀន ដោយពួកគេត្រូវបានកំណត់ថាជា "សិស្ស" ។*




## តើកុមារធ្វើការរកប្រាក់ ដើម្បីសងកម្ចីមីក្រូហិរញ្ញវត្ថុ ឬធនាគារមួយណា?

| គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬធនាគារ | ក្មេងប្រុស | | ក្មេងស្រី | | សរុប |
|---|---|---|---|---|---|
| | នៅរៀន | ឈប់រៀន | នៅរៀន | ឈប់រៀន | |
| អេស៊ីលីដា | | ១ | | ៣ | ៤ |
| ហត្ថា | | | | ១ | ១ |
| ដាប់ប៊ែលយូ ប៊ី ហ្វាយនែន | ១ | ៣ | | ១ | ៥ |
| ស្ថាបនា | | ១ | | ២ | ៣ |
| អេអឹមខេ | | ៥ | | ៩ | ១៤ |
| ប្រាសាក់ | | ៤ | | ៤ | ៨ |
| វិលអូវិលស៊ី | | ៣ | ១ | | ៤ |
| អម្រឹត | | ៤ | | ៧ | ១១ |
| ស្ថាប័នផ្សេងទៀត | | ៣ | | ៣ | ៦ |
| សរុប | ១ | ២៤ | ១ | ៣០ | ៥៦* |

*ចំនួនកុមារ៥១នាក់ ។ កុមារខ្លះ បានជួយបង់សងកម្ចីឥណទានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬធនាគារជាច្រើន ដូច្នេះចំនួនសរុបក្នុងតារាងមិនស្មើចំនួន ៥១នោះទេ ។

**១៨,៣%**

នៃខ្នងផ្ទះសរុប ដែលបានលើកឡើង ពីការកាត់បន្ថយអាហារបរិភោគ ក្រោយពេលយកកម្ចី

**៨.៥%**

នៃខ្នងផ្ទះសរុប ដែលពុំមានអាហារ បរិភោគគ្រប់គ្រាន់

## អសុវត្ថិភាពស្បៀង

១៨,៣% នៃអ្នកខ្ចី បានលើកឡើងថា ការកាត់បន្ថយការបរិភោគអាហារ ក្រោយពេលជាប់ជំពាក់កម្ចីឥណទាន ខណៈដែលមានតែ ៤,៥% ប៉ុណ្ណោះដែលបានលើកឡើងពី ផលវិជ្ជមានលើការបរិភោគអាហាររបស់ពួកគេ ។ អ្នកខ្ចីប្រាក់ភាគច្រើនបានឆ្លើយតបថា ពុំមានការប្រែប្រួលឡើយ ។

នៅក្នុងសំណួរដាច់ដោយឡែកមួយទៀត អ្នកផ្តល់បទសម្ភាសន៍៦១នាក់ (៨៥%) បាននិយាយថា គ្រួសាររបស់ពួកគេ គ្មានអាហារបរិភោគគ្រប់គ្រាន់ទេ ។ ច្រើនជាងពាក់កណ្តាលនៃប្រជាពលរដ្ឋ ៦១ខ្នងផ្ទះនេះ គឺស្ថិតក្នុងចំណោម ១៨,៣% នៃខ្នងផ្ទះសរុប ដែលកាត់បន្ថយការបរិភោគអាហារក្រោយពេលជាប់បំណុលមីក្រូហិរញ្ញវត្ថុ ឬធនាគារ ។ ករណីនេះបង្ហាញថា ក្នុងចំណោមគ្រួសារទាំងអស់ដែលគ្មានអាហារបរិភោគគ្រប់គ្រាន់ មានជាងពាក់កណ្តាលដែលមានផលប៉ះពាល់អវិជ្ជមានលើការបរិភោគអាហាររបស់ពួកគេ ដោយសារកម្ចីមីក្រូហិរញ្ញវត្ថុ ឬធនាគារ ។

### តើគ្រួសារអ្នកបរិភោគអាហារក្នុងកម្រិតណា ក្រោយពេលជាប់កម្ចី?




### តើអ្នកមានអារម្មណ៍ថា គ្រួសាររបស់អ្នកមានអាហារបរិភោគគ្រប់គ្រាន់ដែរទេ?




**៥,១%**

អ្នកផ្តល់បទសម្ភាសន៍លើកឡើងពីការបរិភោគអាហារតិចជាងមុនពេលយកកម្ចី ហើយគ្រួសាររបស់ពួកគេពុំមានអាហារគ្រប់គ្រាន់ដើម្បីបរិភោគទេ

## ភាពញឹកញាប់នៃផលប៉ះពាល់

ទិន្នន័យនៅក្នុងការស្ទង់មតិ អនុញ្ញាតឱ្យយើង ប៉ាន់ប្រមាណពីភាគរយនៃចំនួនខ្នងផ្ទះទាំងអស់ នៅក្នុងខេត្តកំពង់ស្ពឺ ដែលបច្ចុប្បន្នកំពុងជាប់បំណុលផ្លូវការរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬធនាគារ (៨១,៧%) ។ ការប៉ាន់ស្មាននេះ គឺស្ទើរតែដូចគ្នាទៅនឹងអត្រានៃការជ្រៀតចូលនៃកម្ចីផ្លូវការ ដែលត្រូវបានរាយការណ៍ដោយការស្ទង់មតិបែបបរិមាណ ក្រោមការគាំទ្រជំនួយថវិកាឧស្សាហកម្មនេះ កាលពីឆ្នាំ២០១៧ (៨២%) ។ ដោយប្រើប្រាស់អត្រានេះ ការស្ទង់មតិរបស់យើងខ្ញុំ បង្ហាញថានៅទូទាំងខេត្តកំពង់ស្ពឺមាន៖

- ប្រជាពលរដ្ឋ **១៥៧,៤១៣ខ្នងផ្ទះ** កំពុងជាប់ជំពាក់កម្ចីផ្លូវការពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬធនាគារ យ៉ាងតិចមួយ
- ប្រជាពលរដ្ឋ **១៤៤.៨១៩ខ្នងផ្ទះ** បានដាក់ធានាប្លង់កម្មសិទ្ធិដីធ្លីយ៉ាងតិចមួយ សម្រាប់កម្ចីផ្លូវការពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬធនាគារ ។
- ប្រជាពលរដ្ឋ **៩.៦០២ខ្នងផ្ទះ** បានលក់ដីដើម្បីសងកម្ចីផ្លូវការពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬធនាគារ ។
- ប្រជាពលរដ្ឋ **២៨.៨០៦ខ្នងផ្ទះ** កំពុងកាត់បន្ថយការបរិភោគអាហារ ក្រោយពេលយកកម្ចីផ្លូវការពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬធនាគារ ។
- ប្រជាពលរដ្ឋ **៤២.៩៧៣ខ្នងផ្ទះ** កំពុងប្រើប្រាស់ប្រាក់ចំណូលរបស់ពួកគេជាង ៧០% ដើម្បីបង់សងបំណុល ជារៀងរាល់ខែ ។
- កុមារចំនួន **៨.៩១២នាក់** បានឈប់រៀន ដោយសារកម្ចីមីក្រូហិរញ្ញវត្ថុ ឬធនាគារ នៅទូទាំងខ្នងផ្ទះសរុប ៤.៥៦៥ ។

### វិធីគណនាការប៉ាន់ស្មានទាំងនេះ

ពុំមានការបង្ហាញទិន្នន័យណាមួយ អំពីចំនួនខ្នងផ្ទះសរុបនៅក្នុងខេត្តកំពង់ស្ពឺ ដែលបានយកកម្ចីផ្លូវការពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬធនាគារ នៅរយៈពេល១០ឆ្នាំចុងក្រោយនេះទេ ។

ប៉ុន្តែដោយផ្អែកលើទិន្នន័យឧស្សាហកម្មនេះ យើងអាចដឹងថា៖

មានកម្ចីផ្លូវការពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬធនាគារ ដែលនៅបន្តបង់សងនៅក្នុងខេត្តកំពង់ស្ពឺចំនួន ១៩២.៥០៥កម្ចី (គិតត្រឹមពាក់កណ្ដាលឆ្នាំ២០២១) ។

ផ្អែកលើការឆ្លើយតបនៅក្នុងការស្ទង់មតិនេះ យើងអាចដឹងថា៖

ប្រជាពលរដ្ឋចំនួន៦២៨ ខ្នងផ្ទះ ដែលកំពុងជាប់ជំពាក់កម្ចីផ្លូវការនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬធនាគារ ចំនួន ៧៦៨កម្ចី ដោយជាមធ្យមគឺប្រជាពលរដ្ឋមួយខ្នងផ្ទះ កំពុងមានជាប់កម្ចីផ្លូវការចំនួន ១,២២កម្ចី ។

ដោយសារការស្ទង់មតិរបស់យើង គឺជាស្ថិតិតំណាងនៃចំនួនខ្នងផ្ទះដែលយកកម្ចីផ្លូវការពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬធនាគារ យើងអាចយកផលធៀបនេះបាន (១,២២កម្ចីដែលកំពុងជាប់ជំពាក់ជាមួយកម្ចីផ្លូវការពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬធនាគារក្នុងមួយខ្នងផ្ទះ) ហើយអនុវត្តវាជាមួយទិន្នន័យឧស្សាហកម្ម (កម្ចីផ្លូវការចំនួន ១៩២.៥០៥ ដែលកំពុងជាប់ជំពាក់ជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬធនាគារ នៅក្នុងខេត្តកំពង់ស្ពឺ) ដើម្បីប៉ាន់ប្រមាណចំនួនខ្នងផ្ទះនៅក្នុងខេត្តកំពង់ស្ពឺ ដែលកំពុងជាប់កម្ចីផ្លូវការពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬធនាគារ ។

នេះបង្ហាញពីលទ្ធផលនៃការរកឃើញ ប្រជាពលរដ្ឋប្រមាណជា ១៥៧.៤១៣ខ្នងផ្ទះ កំពុងជំពាក់កម្ចីឥណទានផ្លូវការពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬធនាគារ នៅក្នុងខេត្តកំពង់ស្ពឺ ប្រមាណជា ៨១,៧%នៃ១៩៥.៨៨២ ខ្នងផ្ទះ នៅក្នុងខេត្ត ។ នេះគឺស្ទើរតែដូចគ្នាទៅនឹង អត្រា៨២%នៃការជ្រៀតចូលឥណទានផ្លូវការ សម្រាប់ខេត្តកំពង់ស្ពឺ ដែលបានរាយការណ៍នៅក្នុងឆ្នាំ២០១៧ ពី "*ភាពជាប់ជំពាក់បំណុលច្រើនលើសលប់នៅកម្ពុជា II*" ដែលការស្ទង់មតិតំណាងនេះ ធ្វើឡើងដោយវិនិយោគិនក្នុងវិស័យមីក្រូហិរញ្ញវត្ថុជាច្រើន ។[១៧]

ផលធៀបនេះ អនុញ្ញាតឱ្យមានការប៉ាន់ស្មានពីភាពញឹកញាប់នៃផលប៉ះពាល់ ទៅលើខ្នងផ្ទះទាំងអស់ នៅក្នុងខេត្តកំពង់ស្ពឺ ដូចដែលបានបង្ហាញខាងលើ ។

[២] ទោះបីជារបាយការណ៍ដំបូងស្ដីពី "ភាពជំពាក់បំណុលច្រើនលើសលប់នៅកម្ពុជា" បានចេញផ្សាយជាសាធារណៈក្ដី ប៉ុន្តែរបាយការណ៍ទី២ក្នុងឆ្នាំ២០១៧ មិនធ្លាប់ត្រូវបានចេញផ្សាយនោះទេ ។




# សេចក្តីសន្និដ្ឋាន

លទ្ធផលនៃការស្ទង់មតិនេះ បានបន្ថែមទៅលើអ្វីដែលជាភស្តុតាងដ៏សំខាន់ និងក្នុងទំហំធំ ដែលបង្ហាញពីវិបត្តិមីក្រូហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា ដែលកំពុងប៉ះពាល់ដល់វិបត្តិសិទ្ធិមនុស្ស ។

ភាគច្រើននៃការរកឃើញទាំងនេះ បង្ហាញជាថ្មីម្តងទៀត និងគាំទ្រ ការរកឃើញនៅក្នុងការស្រាវជ្រាវ និងរបាយការណ៍ផ្សេងទៀត ទៅលើវិបត្តិនេះ ។ ទោះបីជាមានភស្តុតាងទាំងនេះ ស្ថាប័នជាច្រើននៅក្នុងវិស័យហិរញ្ញវត្ថុនៅកម្ពុជា រួមមានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ វិនិយោគិន និងតួអង្គនៃឧស្សាហកម្មនេះ នៅតែបន្តភាពមិនច្បាស់លាស់ និងមើលរំលង ការកើនឡើងនៃភាពបន្ទាន់ក្នុងការចាត់វិធានការ ដើម្បីបញ្ឈប់វិបត្តិនេះ ។

អង្គការលីកាដូ អង្គការសមធម៌កម្ពុជា និងអង្គការមិនមែនរដ្ឋាភិបាលដៃគូផ្សេងទៀត កំពុងតែបង្កើនការជួយអ្នកខ្ចីប្រាក់ដែលកំពុងរងគ្រោះយ៉ាងធ្ងន់ធ្ងរពីការរំលោភសិទ្ធិមនុស្ស និងការខូចខាតផ្សេងៗ ដោយសារបំណុលមីក្រូហិរញ្ញវត្ថុរបស់ពួកគេ ។ ប្រជាពលរដ្ឋខ្មែរអ្នកខ្ចីប្រាក់ គឺជាក្រុមមនុស្សដែលកំពុងរងគ្រោះពីកង្វះនៃកិច្ចការពារអ្នកប្រើប្រាស់ និងការផ្តល់កម្ចីបែបកេងប្រវ័ញ្ចជាច្រើនឆ្នាំ ពីសំណាក់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលរកប្រាក់ចំណេញបានខ្ពស់ ។ ភាពរងគ្រោះរបស់ពួកគេ តែងតែត្រូវបានមើលរំលង ឬគ្មានការយកចិត្តទុកដាក់ ដោយវិនិយោគិន ដែលបានបរាជ័យក្នុងការអនុវត្តឱ្យបានគ្រប់គ្រាន់នូវវិធានការហ្មត់ចត់ ទៅលើផលប៉ះពាល់នៅក្នុងវិស័យនេះ ។

ជាមួយគ្នាផងដែរ សំឡេងធំបំផុតនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ និងធនាគារ នៅតែបន្តព្យាយាមបដិសេធភស្តុតាងនៃផលប៉ះពាល់ទាំងនេះ ទោះបីជាត្រូវបានរកឃើញដោយអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក វិនិយោគិនអន្តរជាតិ អ្នកស្រាវជ្រាវកម្រិតខ្ពស់ ឬអ្នកសារព័ត៌មាន ក៏ដោយ ។ ផ្ទុយទៅវិញ គឺមានតែការព្យាយាមបន្តុះបង្អាប់ដល់ការស្រាវជ្រាវឯករាជ្យ និងជឿទុកចិត្តបាន ព្រមទាំងបង្វែរការសន្ទនាឱ្យចាកឆ្ងាយពីឯកសារផ្អែកលើភស្តុតាង ដែលគួរតែត្រូវបានអនុវត្តឱ្យបានឆាប់ពីតម្រូវការនៃដំណោះស្រាយ និងការអនុគ្រោះសម្រាប់អ្នកខ្ចីប្រាក់ដែលរងគ្រោះ ។

អង្គការមិនមែនរដ្ឋាភិបាល អាចបន្តលើកឡើងពីបញ្ហានេះ និងផ្តល់ភស្តុតាងនៃទំហំ និងផលប៉ះពាល់ធ្ងន់ធ្ងរនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ប៉ុន្តែយើងខ្ញុំមិនមានសមត្ថភាព ក្នុងការបញ្ឈប់ការប្រើប្រាស់ប័ណ្ណកម្មសិទ្ធិដីធ្លីធ្វើជាទ្រព្យធានាទេ ហើយក៏មិនអាចអនុវត្តដំណោះស្រាយ និងការអនុគ្រោះសម្រាប់អ្នកខ្ចីដែលរងគ្រោះផងដែរ ។ អ្វីដែលជាតម្រូវការចាំបាច់នោះគឺ ការចាត់វិធានការពីដៃគូពាក់ព័ន្ធដូចជា វិនិយោគិន អ្នកតាក់តែងច្បាប់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ធនាគារ និងដៃគូអភិវឌ្ឍន៍ ដើម្បីចាប់ផ្តើមអនុវត្តដំណោះស្រាយទាំងនេះ ។ ការបរាជ័យក្នុងការកាត់បន្ថយបន្ទុកបំណុល និងការលុបចោលការអនុវត្តដោយបង្ខំ ជុំវិញការដាក់ដីធ្លីជាទ្រព្យធានា នឹងនាំឱ្យមានផលប៉ះពាល់បន្ថែមទៀត និងផលអាក្រក់កាន់តែខ្លាំងទៅលើវិបត្តិសិទ្ធិមនុស្សដែលកំពុងកើតមាន ក្នុងចំណោមអ្នកខ្ចីកម្ចីឥណទានខ្នាតតូច គ្រួសារ និងសហគមន៍របស់ពួកគេ ។

# អនុសាសន៍

ជាថ្មីម្តងទៀត យើងខ្ញុំ សូមអំពាវនាវឱ្យមានការអនុវត្តច្បាប់ដែលមានស្រាប់ និងធ្វើកំណែទម្រង់វិស័យមីក្រូហិរញ្ញវត្ថុ ឱ្យស្របតាមគោលការណ៍ណែនាំរបស់ អង្គការសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ (OECD) គោលនយោបាយធនាគារអភិវឌ្ឍន៍ និងគោលការណ៍សិទ្ធិមនុស្សនានា ។ ជាពិសេស យើងខ្ញុំ សូមផ្តល់អនុសាសន៍ម្តងទៀតចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ វិនិយោគិនរបស់ពួកគេ និងរាជរដ្ឋាភិបាលដូចជា៖

- សូមឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជា បញ្ឈប់ការលក់ដីដោយបង្ខំក្រៅប្រព័ន្ធតុលាការ បញ្ឈប់ការអនុវត្តការផ្តល់កម្ចីឥណទានបែបកេងប្រវ័ញ្ច និងចាត់វិធានការចាំបាច់ ដើម្បីកាត់បន្ថយចំនួននៃការលក់ដី ដែលតម្រូវឱ្យបង់សងបំណុល ។[១៨]

- សូមផ្តល់ការអនុគ្រោះបំណុល និងសំណងសមរម្យ សម្រាប់អ្នកខ្ចីប្រាក់ ដែលរងគ្រោះពីការរំលោភសិទ្ធិមនុស្ស កើតចេញពីកម្ចីឥណទានខ្នាតតូចបែបកេងប្រវ័ញ្ច ។[១៩]

- សូមកែប្រែបទបញ្ជាផ្ទៃក្នុងរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដើម្បីហាមឃាត់ការតម្រូវឱ្យដាក់ប័ណ្ណកម្មសិទ្ធិដីធ្លី ជាទ្រព្យធានា សម្រាប់កម្ចីមីក្រូហិរញ្ញវត្ថុថ្មីៗទាំងអស់ ។[២០]

- សូមប្រគល់ប័ណ្ណកម្មសិទ្ធិដីធ្លីទាំងអស់ ដែលកំពុងដាក់ជាទ្រព្យធានា ឱ្យទៅម្ចាស់គេវិញ ៕[២១]

---

[១៨] អនុសាសន៍ដំបូងនៅក្នុងរបាយការណ៍ "ការធ្វើឱ្យខូចខាតទ្រព្យដាក់បញ្ចាំ" កាលពីខែសីហា ឆ្នាំ២០១៩ ។

[១៩] អនុសាសន៍ដំបូងនៅក្នុងរបាយការណ៍ "សិទ្ធិទទួលបានការអនុគ្រោះ" កាលពីខែមិថុនា ឆ្នាំ២០២១ ។

[២០] អនុសាសន៍ដំបូងនៅក្នុងរបាយការណ៍ "ការធ្វើឱ្យខូចខាតទ្រព្យដាក់បញ្ចាំ" កាលពីខែសីហា ឆ្នាំ២០១៩ ។

[២១] អនុសាសន៍ដំបូងនៅក្នុងរបាយការណ៍ "សិទ្ធិទទួលបានការអនុគ្រោះ" កាលពីខែមិថុនា ឆ្នាំ២០២១ ។

www.mficambodia.com

www.licadho-cambodia.org

www.equitablecambodia.org